ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ
# និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩
# តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣

រៀបចំដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែ ធ្នូ ឆ្នាំ ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១២២ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់នូវក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តី-ពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តី-ពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវ «ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣» ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។



Scan QR Code

**ប្រការ៣**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់-ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អារម្ភកថា

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ, ស្ថិតនៅក្រោមដំបូលនៃសន្តិភាព និង ស្ថិរភាពពេញលេញ, រាជរដ្ឋាភិបាលបានដាក់ចេញ និង អនុវត្តជាបន្តបន្ទាប់ នូវ **យុទ្ធសាស្ត្រចតុកោណ** និង កម្មវិធីកែទម្រង់សំខាន់ៗ ព្រមទាំងបានបង្កើនចំណាយសាធារណៈយ៉ាងច្រើន សំដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមជាតិទាំងមូល ។ ជាលទ្ធផល, កម្ពុជាសម្រេចបានកំណើនខ្ពស់ ដែលបានចូលរួមយ៉ាងខ្លាំងក្លាគួរជាទីមោទនៈ ក្នុងការបង្កើតការងារ និង ការកាត់បន្ថយអាត្រានៃភាពក្រីក្រ ជាពិសេសការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។ យ៉ាងណាមិញ, ក្នុងឆ្នាំ ២០២០, ពិភពលោកបានជួបនឹងព្រឹត្តិការណ៍ដ៏អាក្រក់មួយ ដែលបង្កជាបច្ច័យអវិជ្ជមានពុំធ្លាប់មានពីមុនមក, ទាំងចំពោះសុខភាពសាធារណៈ និង សង្គម-សេដ្ឋកិច្ច, ពោលគឺ វិបត្តិជំងឺកូវីដ-១៩ ។ អស់រយៈពេលជិត ២ ឆ្នាំកន្លងទៅ, វិបត្តិនេះ បានឆក់យកអាយុជីវិតមនុស្សរាប់លាននាក់ និង បានរុញច្រានសេដ្ឋកិច្ចសកល ឱ្យធ្លាក់ក្នុងវិបត្តិ និង ចោទជាបញ្ហាប្រឈមទៅលើគន្លងនៃការអភិវឌ្ឍរយៈពេលវែង, ទាំងក្នុងក្របខណ្ឌសកល, តំបន់, និង ប្រទេសនីមួយៗ ។

ជាមួយនឹងវឌ្ឍនភាពល្អប្រសើរក្នុងការផលិត និង ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ ទូទាំងសកលលោក, ប្រទេសភាគច្រើន បាន និង កំពុងចាត់ទុកវ៉ាក់សាំងជាយុទ្ធសាស្ត្រគន្លឹះ សម្រាប់បើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ច និង គិតគូរជំរុញការស្តារ និង លើកស្ទួយសេដ្ឋកិច្ចឡើងវិញ ។ ទោះជាយ៉ាងនេះក្តី, រហូតមកដល់បច្ចុប្បន្ន, វីរុសកូរ៉ូណានៅតែបន្តបំប្លែងខ្លួនយ៉ាងសកម្មទៅជាប្រភេទថ្មីៗជាច្រើនដែលមានលទ្ធភាពចម្លងកាន់តែខ្ពស់ និង អាចបង្កហានិភ័យដល់សុខភាពសាធារណៈកាន់តែធ្ងន់ធ្ងរ ។ ការណ៍នេះ នឹងធ្វើឱ្យវិបត្តិជំងឺកូវីដ-១៩ នៅតែបន្តអូសបន្លាយ ជាមួយនឹងភាពមិនប្រាកដប្រជាខ្ពស់ ។ ដូច្នេះ, ចៀសមិនផុត, ដំណើរនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ នឹងត្រូវធ្វើឡើងក្នុងបរិការណ៍នៃការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ។

សម្រាប់កម្ពុជា, ក្នុងឆ្នាំ ២០២០, សេដ្ឋកិច្ចជាតិសម្រេចបានកំណើនអវិជ្ជមាន ដែលពុំធ្លាប់មានពីមុនមក ដោយសារវិស័យជំរុញកំណើនសំខាន់ៗ រួមមាន វិស័យទេសចរណ៍ និង វិស័យគាំទ្រផ្សេងទៀត ដូចជា កាត់ដេរ, សំណង់ និង អចលនទ្រព្យ បានធ្លាក់យ៉ាងគំហុក ។ ជាការពិត, សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើនអវិជ្ជមានជ្រៅជាងនេះ ក្នុងករណីពុំមានការដាក់ចេញជាបន្តបន្ទាប់កន្លងមក នូវវិធានការអន្តរាគមន៍ទាន់ពេល និង ប្រកបដោយប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល ដែល, ម្ខាង, សំដៅជានាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, និងម្ខាងទៀត, សំដៅរក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជនដែលទទួលរងផលប៉ះពាល់ខ្លាំង ។ ជាមួយគ្នា, រាជរដ្ឋាភិបាលក៏បន្តខិតខំទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស តាមរយៈការអនុវត្តយុទ្ធសាស្ត្រវ៉ាក់សាំង ដែលឈរលើគោលការណ៍ជាក់ស្តែងនិយម និង ទន់ភ្លន់, ប៉ុន្តែ ម៉ឺងម៉ាត់ ព្រមទាំងបត់បែនទាន់ពេល ទៅតាមសភាពការណ៍តម្រូវ ។ ជាលទ្ធផល, រាជរដ្ឋាភិបាលសម្រេចបាននូវអត្រាចាក់វ៉ាក់សាំងជូនប្រជាជន ក្នុងកម្រិតមួយខ្ពស់ ធៀបនឹងប្រទេសផ្សេងទៀត, ទាំងក្នុងក្របខណ្ឌតំបន់ និង សកល, ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការឈានទៅសម្រេចបាននូវ "**ភាពស៊ាំសហគមន៍**" នៅក្នុងប្រទេស និង ដែលបានធ្វើឱ្យអត្រាឆ្លង ក៏ដូចជាអត្រាចូលសម្រាកពេទ្យ និង អត្រាមរណភាព មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ។ លើមូលដ្ឋាននេះ, ថ្មីៗនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវ "**យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩**" ជាមួយនឹងទស្សនវិស័យនៃការចាកចេញពី



Scan QR Code

វិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំ និង ការវិលត្រលប់ទៅរកមាគ៌ានៃកំណើន និង ការអភិវឌ្ឍប្រកបដោយចីរភាពឡើងវិញ ។

ដំណាលគ្នា, រាជរដ្ឋាភិបាលក៏បានគិតគូរផងដែរ អំពីការរៀបចំដាក់ចេញនូវយុទ្ធសាស្ត្រ និងកញ្ចប់នៃវិធានការគោលនយោបាយដើម្បីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា រួមបញ្ចូលទាំងការ-ចាប់យកកាលានុវត្តភាពថ្មីៗពីវិបត្តិនេះ ដោយផ្តោតជាចម្បងលើការកែទម្រង់ និង ការដោះស្រាយបញ្ហាប្រឈមសំខាន់ៗ, ទាំងក្នុងពេលចំពោះមុខ និង ទាំងក្នុងរយៈពេលមធ្យម, សំដៅលើកកម្ពស់បរិយាកាសវិនិយោគ និង បង្កើនភាពងាយស្រួលក្នុងការធ្វើធុរកិច្ច ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលរំពឹងយ៉ាងមុតមាំថា **"ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"**, ដែលត្រូវបានដាក់ចេញក្នុងពេលនេះ, នឹងដើរតួនាទីជាផែនទីបង្ហាញផ្លូវ និង ជាកម្លាំងចលករដ៏មានប្រសិទ្ធភាព សម្រាប់ការពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ឱ្យរស់រវើកឡើង ក៏ដូចជាសម្រាប់ការចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់ និង សកល ដើម្បីលើកកម្ពស់កំណើនប្រកបដោយចីរភាព និង ដែលកាន់តែមានពិពិធកម្ម ក៏ដូចជាដើម្បីកសាងភាពធន់ដ៏រឹងមាំនៃសង្គម-សេដ្ឋកិច្ច ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** (គ.ស.ហ.), ក្នុងការដឹកនាំគណៈកម្មាធិការអន្តរក្រសួង-ស្ថាប័ន និង ក្រុមការងារបច្ចេកទេស ដើម្បីរៀបចំសម្រេចបាននូវឯកសារក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ ដ៏មានសារៈសំខាន់នេះឡើង យ៉ាងឆាប់ និង ទាន់ពេល ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណ និង សម្តែងនូវការវាយតម្លៃខ្ពស់ ជូនដល់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ដែលជាថ្នាក់ដឹកនាំ និង តំណាងនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ព្រមទាំងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ស.ហ.** ចំពោះការចូលរួមយ៉ាងសកម្ម និង ប្រកបដោយការទទួលខុសត្រូវ ក្នុងការរៀបចំឯកសារនេះ ។

នៅចុងបញ្ចប់, ជាមួយនឹងការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការ នូវ **"ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** នេះ, ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ក្រសួង-ស្ថាប័ន និង តួអង្គ ដែលមានការពាក់ព័ន្ធ ឱ្យសកម្មចូលរួមអនុវត្តបណ្តាវិធានការដែលមានចែងនៅក្នុងឯកសារនេះ ក្នុងឆន្ទៈមោះមុតប្រកបដោយស្មារតីទទួលខុសត្រូវ និង កិច្ចសហការខ្ពស់ សំដៅជានាសម្រេចបានជោគជ័យ និង លទ្ធផលជាក់ស្តែង តាមការរំពឹងទុក ។

ថ្ងៃ[illegible] ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


**ផ្នែកទី ១៖ សេចក្តីផ្តើម** ............ ១

**១.១. ស្ថានភាព និងផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩** ............ ២

ក. ស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ............ ២

ខ. ផលប៉ះពាល់នៃវិបត្តិនៃជំងឺកូវីដ-១៩ ............ ៣

**១.២. វិបានការអន្តរាគមន៍ និងនិន្នាការនៃសេដ្ឋកិច្ចសកល** ............ ៤

ក. វិបានការអន្តរាគមន៍ ............ ៤

ខ. និន្នាការសេដ្ឋកិច្ចសកល ............ ៤

**១.៣. ទស្សនវិស័យសម្រាប់កម្ពុជា** ............ ៥

ក. មេរៀន និងបទពិសោធន៍ពីវិបត្តិនៃជំងឺកូវីដ-១៩ ............ ៥

ខ. ភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា ............ ៦

**ផ្នែកទី ២៖ ទស្សនាទានរួម** ............ ៨

**២.១. ចក្ខុវិស័យ** ............ ៨

**២.២. គោលបំណង និងគោលដៅ** ............ ៩

**២.៣. អភិក្រមរួមសម្រាប់ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធី** ............ ៩

**ផ្នែកទី ៣៖ ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាតាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣** ............ ១០

**៣.១. ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ** ............ ១០

៣.១.១. វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ............ ១១

៣.១.២. វិស័យទេសចរណ៍ ............ ១១

៣.១.៣. វិស័យកាត់ដេរ ............ ១២

៣.១.៤. វិស័យកម្មន្តសាលមិនមែនកាត់ដេរ ............ ១៣

**៣.២. ការកែទម្រង់ ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន, ពិពិធកម្ម និងភាពប្រកួតប្រជែង** ............ ១៤

៣.២.១. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ ............ ១៤

៣.២.២. ការជំរុញការអនុវត្តច្បាប់វិនិយោគ ............ ១៥

៣.២.៣. វិស័យអគ្គិសនី ............ ១៦

៣.២.៤. ការកែលម្អបរិយាសធុរកិច្ច ............ ១៧

ក. ការស្នើសុំលិខិតអនុញ្ញាតសាងសង់ ............ ១៧

ខ. ការផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យ ............ ១៧

គ. ការលើកកម្ពស់សេវាពន្ធដារ ............ ១៨

ឃ. ការលើកកម្ពស់សេវាគយ និងរដ្ឋាករ ............ ១៨




ផ្ទៀងផ្ទាត់ឯកសារតាមរយៈ | Scan QR Code

ង. ការជំរុញការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីក្រុមហ៊ុន, ការចេញC/O និងកាត់តម្រឹម ការតម្រូវឯកសារដែលមិនចាំបាច់ទាក់ទងនឹងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ... ១៨
ច. ការរៀបចំសហគមន៍អ្នកប្រមូលផលនិងនាំចេញ និងការរៀបចំឃ្លាំង, ឡសម្ងួត និងឧបករណ៍សម្ងាប់សត្វចង្រៃសម្រាប់ផលិតផលនាំចេញ ........ ១៩
៣.២.៥. វិស័យដឹកជញ្ជូន និងឡូជីស្ទីក ........ ១៩
**៣.៣. ការពង្រឹងភាពធន់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ........ ២០**
៣.៣.១. វិស័យឌីជីថល ........ ២០
៣.៣.២. ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ........ ២១
៣.៣.៣. ការអភិវឌ្ឍជំនាញ ........ ២២
៣.៣.៤. ការអភិវឌ្ឍវិស័យអប់រំ ........ ២៣
៣.៣.៥. ប្រព័ន្ធគាំពារសង្គម ........ ២៤
៣.៣.៦. វិស័យសុខាភិបាល ........ ២៥
៣.៣.៧. ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ........ ២៥
៣.៣.៨. ការអភិវឌ្ឍបៃតង ........ ២៦
**ផ្នែកទី ៤៖ កម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០២១-២០២៣ ........ ២៧**
**ផ្នែកទី ៥៖ មធ្យោបាយគាំទ្រការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធី ........ ២៧**
**៥.១. ជម្រើសឧបករណ៍គោលនយោបាយ ........ ២៧**
ក. វិធានការគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន ........ ២៧
ខ. វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ........ ២៨
គ. យន្តការពង្រឹងកិច្ចសហការរវាងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយ ហិរញ្ញវត្ថុសាធារណៈ ........ ២៩
**៥.២. យន្តការហិរញ្ញប្បទាន ........ ២៩**
ក. ការកៀរគរធនធានរបស់រាជរដ្ឋាភិបាល ........ ២៩
ខ. យន្តការហិរញ្ញប្បទានដល់វិស័យឯកជន ........ ៣០
**៥.៣. យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ........ ៣០**
**ផ្នែកទី ៦៖ យន្តការស្ថាប័ន និងការតាមដាន និងវាយតម្លៃ ........ ៣០**
**ផ្នែកទី ៧៖ សេចក្តីសន្និដ្ឋាន ........ ៣១**
**បរិសិដ្ឋ៖ កម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ ២០២១-២០២៣ ........ [illegible]**

## ផ្នែកទី ១៖ សេចក្តីផ្តើម

ចាប់តាំងពីដើមឆ្នាំ ២០២០, ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ទូទាំងពិភពលោកបានប្រែក្លាយជាវិបត្តិសុខាភិបាលសាធារណៈ ដ៏ធ្ងន់ធ្ងរបំផុតមួយក្នុងយុគសម័យទំនើប។ នៅដំណាក់កាលដំបូងនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩, ប្រទេសជាច្រើនបានសម្រេចជ្រើសរើសនូវវិធានការរឹតត្បិតការធ្វើដំណើរ ព្រមទាំងដាក់ចេញនូវវិធានការសុខាភិបាល និងវិធានការរដ្ឋបាលផ្សេងទៀត រួមទាំង ការបិទប្រទេសដោយផ្នែកៗ ឬទាំងស្រុង ជាច្រើនលើកច្រើនសារ ដើម្បីគ្រប់គ្រងការឆ្លងរាលដាល, កាត់បន្ថយផលប៉ះពាល់ និងការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ។ ជាការពិត, ការអនុវត្តនូវវិធានការទាំងនេះ បានបង្កផលប៉ះពាល់ជាអវិជ្ជមានលើខ្សែច្រវាក់ផ្គត់ផ្គង់ និងផលិតកម្ម, ការធ្វើដំណើរ និងទេសចរណ៍, តម្រូវការការងារ, តម្រូវការប្រើប្រាស់, ជីវភាពរស់នៅរបស់ប្រជាជនទូទៅ និងជារួម រុញច្រានឱ្យសង្គម-សេដ្ឋកិច្ចសកលធ្លាក់ក្នុងវិបត្តិ ដែលមិនធ្លាប់មានពីមុនមក បើទោះបីជាមានការដាក់ចេញនូវវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ច និងគោលនយោបាយគាំទ្រជាច្រើនក៏ដោយ។

មកដល់ចុង ឆ្នាំ ២០២១, ការគ្រប់គ្រង និងទប់ទល់ជាមួយនឹងជំងឺកូវីដ-១៩ មានវឌ្ឍនភាពល្អប្រសើរច្រើនជាងមុន ជាពិសេស វ៉ាក់សាំងជាច្រើនប្រភេទត្រូវបានអភិវឌ្ឍ ដោយមានការទទួលស្គាល់ពីអង្គការសុខភាពពិភពលោក និងត្រូវបានអនុញ្ញាតឱ្យចែកចាយ និងប្រើប្រាស់នៅទូទាំងពិភពលោក។ រហូតមកទល់ពេលនេះ, បណ្តាប្រទេសជាច្រើន បាននិងកំពុងអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់ប្រជាជនខ្លួន ប៉ុន្តែក្នុងល្បឿនខុសៗគ្នា ដោយអាស្រ័យលើលទ្ធភាពទទួលបានវ៉ាក់សាំង។

ក្នុងរយៈពេលជិត ២ ឆ្នាំកន្លងមកនេះ, កម្ពុជាបានឆ្លើយតបទៅនឹងវិបត្តិនេះ ប្រកបដោយភាព-ស្វាហាប់ និងភាពបត់បែន ជាមួយនឹងការអនុវត្តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយប្រកបដោយស្មារតីបុរេ-សកម្ម។ នៅក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានកំណត់យកការចាក់វ៉ាក់សាំងជា **វិធានការយុទ្ធសាស្ត្រគន្លឹះ** គួបផ្សំជាមួយនឹងវិធានការ ៣ ទៀត រួមមាន៖ (១). ការខិតខំទប់ស្កាត់ និងរុករកការ-ឆ្លងឱ្យបានទាន់ពេល, (២). ការពង្រឹងសមត្ថភាពព្យាបាល និងការប្រើប្រាស់ថ្នាំព្យាបាលប្រកបដោយស័ក្តិសិទ្ធិភាព, និង (៣). ការអនុវត្តដោយហ្មត់ចត់នូវវិធានការរដ្ឋបាល, សុខាភិបាល និងអប់រំ ជាពិសេស ការជំរុញការចូលរួមយ៉ាងសកម្មពីសំណាក់សាធារណជនពីគ្រប់មជ្ឈដ្ឋាន និងគ្រប់រូប។ នៅក្នុងផ្នែកសង្គម-សេដ្ឋកិច្ច, រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការអន្តរាគមន៍ចំនួន ១០ ជុំ សំដៅជួយរក្សាលំនឹងធុរកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេស កម្មករ-និយោជិត និងគ្រួសារក្រីក្រ ព្រមទាំងជនងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិនៃជំងឺកូវីដ-១៩។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងខាងលើនេះ, កម្ពុជាបានក្លាយជាប្រទេស ដែលមានអត្រាចាក់វ៉ាក់សាំងខ្ពស់ និងបង្កើតបាននូវភាពស៊ាំសហគមន៍ជាបណ្តើរៗ។ គិតត្រឹមថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១, ប្រមាណ ៨៨,៦១% នៃចំនួនប្រជាជនក្នុងប្រទេសសរុប ១៦ លាននាក់ ទទួលបានការចាក់វ៉ាក់សាំង ខណៈពេលដែលការចាក់វ៉ាក់សាំងដូសជំរុញបាននិងកំពុងបន្តជាប្រក្រតី។ ជោគជ័យនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំង និងការគ្រប់គ្រងបានជំងឺកូវីដ-១៩ នៅកម្ពុជា, ព្រមទាំងនិន្នាការធូរស្រាល



ផ្ទៀងផ្ទាត់ឯកសារផ្លូវការ: | Scan QR Code

នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាសកល និងតំបន់ និងលទ្ធផលជាវិជ្ជមាននៃការអភិវឌ្ឍថ្នាំព្យាបាល, ជាកាលានុវត្តភាពដល់កម្ពុជាសម្រាប់បើកទំព័រថ្មីមួយទៀត គឺការរស់នៅជាមួយកូវីដ-១៩ ក្នុងគន្លងប្រក្រតីភាពថ្មី តាមរយៈការបើកដំណើរការជាជំហានៗនូវសកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងគ្រប់វិស័យ និងការស្តារជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនឡើងវិញ។

ដើម្បីគាំទ្រដល់ដំណើរការនេះ, រាជរដ្ឋាភិបាលដាក់ចេញ **"ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** ដែលក្នុងនោះ កម្ពុជានឹងពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចរបស់ខ្លួនឱ្យរស់ឡើងវិញ និងចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីដែលកំពុងលេចឡើងស្របនឹងនិន្នាការសកល និងតំបន់ដើម្បីលើកកម្ពស់ចីរភាពកំណើន និងកសាងភាពធន់រឹងមាំនៃសង្គម-សេដ្ឋកិច្ច។ ការវាយតម្លៃស្ថានភាពទូទៅ និងផលប៉ះពាល់នៃវិបត្តិនៃជំងឺកូវីដ-១៩ ព្រមទាំងការលេចឡើងនៃនិន្នាការសកលសំខាន់ៗ ព្រមទាំងការដកស្រង់បទពិសោធន៍ផ្ទាល់របស់កម្ពុជាក្នុងការប្រយុទ្ធនឹងវិបត្តិនេះ គឺជាមូលដ្ឋានគន្លឹះ ក្នុងការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ឱ្យមានភាព-គ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងគោលបំណងនៃគោលនយោបាយ ដែលបានកំណត់។

## ១.១. ស្ថានភាព និងផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩

### ក. ស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

គិតត្រឹមថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១ អ្នកឆ្លងជំងឺកូវីដ-១៩ នៅទូទាំងសកលលោកមានប្រមាណជាង ២៦៦ លាននាក់ និងបានសម្លាប់មនុស្សជាង ៥,២ លាននាក់ ដែលក្នុងនោះ តំបន់អាមេរិក និងអឺរ៉ុប មានអ្នកឆ្លង និងករណីស្លាប់ច្រើនជាងគេ។ ទោះជាយ៉ាងនេះក្តី, ស្ថានភាពនៃការឆ្លងនៅតំបន់ទាំងនេះ បានចាប់ផ្តើមបង្ហាញសញ្ញានៃភាពធូរស្រាល។ ការវិវត្តពេលខាងមុខ គឺអាស្រ័យខ្លាំងទៅលើល្បឿននៃការបំប្លែងខ្លួនថ្មីនៃមេរោគនៃជំងឺកូវីដ-១៩, ល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ កម្រិតសកល ព្រមទាំងការអភិវឌ្ឍ និងការប្រើប្រាស់ថ្នាំព្យាបាល។

ទន្ទឹមនេះ, អង្គការសុខភាពពិភពលោក បានដាក់ចេញនូវ **"យុទ្ធសាស្ត្រដើម្បីសម្រេចបានការ-ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាសកលលោក ក្នុងពាក់កណ្តាលឆ្នាំ ២០២២"** ក្នុងគោលបំណងសម្រេចបាននូវអត្រាចាក់វ៉ាក់សាំង ៤០% ត្រឹមចុងឆ្នាំ ២០២១ និង ៧០% ត្រឹមពាក់កណ្តាលឆ្នាំ ២០២២ ក្នុងកម្រិតសកល។ គិតត្រឹមថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១, អត្រាចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺកូវីដ-១៩ ក្នុងកម្រិតសកលសម្រេចបានប្រមាណ ៤០,១% នៃចំនួនប្រជាជនសរុប ដែលត្រូវទទួលការចាក់។ ជាការកត់សម្គាល់, ការទទួលបានការចាក់វ៉ាក់សាំងនៅបណ្តាប្រទេសកំពុងអភិវឌ្ឍនៅមានកម្រិតទាបនៅឡើយ។ គួយ៉ាង, ប្រទេសជាង ៥០ ដែលភាគច្រើនជាប្រទេសកំពុងអភិវឌ្ឍមិនអាចសម្រេចបាននូវគោលដៅចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានពេញលេញ សម្រាប់ប្រជាជនយ៉ាងតិច ១០% ត្រឹមចុងខែ កញ្ញា ឆ្នាំ ២០២១ ដែលបានកំណត់ដោយអង្គការសុខភាពពិភពលោកនៅឡើយទេ។

ចំពោះកម្ពុជាវិញ, កម្រិតឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ត្រូវបានរកឃើញថា មានកម្រិតមធ្យម និងស្ថិតនៅក្រោមការគ្រប់គ្រងបាន តាមរយៈការឆ្លើយតបយ៉ាងទាន់ពេល ប្រកបដោយស្មារតីប្រុងប្រយ័ត្ន, បុរេសកម្ម និងទទួលខុសត្រូវខ្ពស់។ គិតត្រឹមថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១, ស្ថានភាពអ្នកឆ្លងសរុប ជាពិសេសអ្នកឆ្លងពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ រហូតដល់ ១២០ ១៨៣ ករណី ដែលក្នុងនោះ មានការបាត់បង់ជីវិតចំនួន ២ ៩៤៩ ករណី។ ជាមួយគ្នានេះ, យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល តាមរយៈ **អភិក្រមផ្ការីក** ដោយចាប់ផ្តើមពីតំបន់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ ទទួលបានជោគជ័យជាទីមោទនៈ ដោយសម្រេចបានអត្រាចាក់វ៉ាក់-សាំងក្នុងកម្រិតប្រមាណជាង ៨៨.៦១% នៃប្រជាជនសរុបចំនួន ១៦ លាននាក់។ អត្រានេះបានធ្វើឱ្យកម្ពុជា សម្រេចបាននូវកម្រិតភាពស៊ាំក្នុងសហគមន៍រឹងមាំ ដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់ សម្រាប់ការ-បើកដំណើរការឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ច ទៅតាមគន្លងប្រក្រតីភាពថ្មី។

## ខ. ផលប៉ះពាល់នៃវិបត្តិនៃជំងឺកូវីដ-១៩

ជារួម ក្នុងឆ្នាំ ២០២០, ជំងឺកូវីដ-១៩ បានបង្កនូវទុក្ខលំបាក ដែលគ្របដណ្តប់សឹងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវភាពរស់នៅរបស់ប្រជាជន និងបង្ខំឱ្យរោងចក្រ-សហគ្រាសទាំងក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធមួយចំនួន បិទអាជីវកម្ម និងផ្អាកដំណើរការ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានវាយតម្លៃថា សេដ្ឋកិច្ចសកលលោក និងពាណិជ្ជកម្មអន្តរជាតិ មានកំណើនអវិជ្ជមាន -៣,៣% និង -៨,៥% រៀងគ្នា។ ធនាគារពិភពលោក (WB) បានរាយការណ៍ថា មនុស្សចន្លោះពី ៨៨ លាននាក់ទៅ ១១៥ លាននាក់បន្ថែម អាចនឹងធ្លាក់ក្នុងស្ថានភាពក្រីក្រ (ចំណូលប្រចាំថ្ងៃទាបជាង ១,៩ ដុល្លារអាមេរិក)។ បន្ថែមលើនេះ, អង្គការពលកម្មអន្តរជាតិ (ILO) បានបង្ហាញថា ចំនួនការងារប្រមាណ ២៥៥ លានកន្លែង ត្រូវបានបាត់បង់ ដែលក្នុងនោះការងារពេញម៉ោងចំនួន ១៤០ លាន រំពឹងថានឹងបាត់បង់ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលក្នុងនោះ ស្ត្រី និងមនុស្សវ័យក្មេងទទួលរងផលប៉ះពាល់ខ្លាំងជាងគេ។ គិតត្រឹមឆ្នាំ ២០២០, ចំណូលពលកម្មសកលបានធ្លាក់ចុះក្នុងអត្រា -៨,៣% ធៀបនឹងក្នុងឆ្នាំ ២០១៩ សមមូលនឹង ៣,៧ ទ្រីលានដុល្លារអាមេរិក ឬ ៤,៤% នៃ ផសស សកលលោកសរុប ក្នុងឆ្នាំ ២០១៩ ដែលក្នុងនោះ ប្រទេសមានចំណូលមធ្យមកម្រិតទាប ទទួលរងផលប៉ះពាល់ច្រើនជាងគេ។

ដោយជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្ពស់, កម្ពុជាមិនអាចគេចរួចពីផលអវិជ្ជមានមកលើសង្គម-សេដ្ឋកិច្ចនោះទេ ជាពិសេស ចាប់តាំងពីត្រីមាសទី ២ នៃឆ្នាំ ២០២០ ដែលរលកនៃការឆ្លងរាល-ដាលនៃជំងឺកូវីដ-១៩ បានដាក់សម្ពាធយ៉ាងខ្លាំងមកលើសកម្មភាពពាណិជ្ជកម្ម, ធុរកិច្ច និងវិនិយោគ។ វិស័យទេសចរណ៍ បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាងគេ ដោយសារការដាក់ចេញវិធានការហាមឃាត់ការធ្វើដំណើរ ព្រមទាំងវិធានការផ្សេងៗបន្ថែមទៀត ពីបណ្តាប្រទេសនៅលើសកលលោក។ ក្នុងឆ្នាំ ២០២០, កម្ពុជាទទួលបានភ្ញៀវទេសចរបរទេសត្រឹមប្រមាណ ១,៣១ លាននាក់ ប៉ុណ្ណោះ ពោលគឺធ្លាក់ចុះក្នុងអត្រា -៨០,២% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៩។ ជាលទ្ធផល, សេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមានក្នុងអត្រា -៣,១% ហើយអត្រាភាពក្រីក្រត្រូវបានប៉ាន់ស្មានថាកើនឡើងដល់ ១៧,៨% ក្នុងឆ្នាំ ២០២០ ដោយសារការបាត់បង់ការងារ។ ក្នុងនោះ សម្រាប់វិស័យទេសចរណ៍, កម្មករ-និយោជិតប្រមាណ ១០ ម៉ឺននាក់ បានបាត់បង់ការងារស្ទើរទាំងស្រុង ខណៈកម្មករ-និយោជិត ១០ ម៉ឺននាក់



Scan QR Code

ទៀត បាត់បង់ការងារមួយផ្នែក ឬតម្រូវឱ្យធ្វើការឆ្លាស់វេន និងមនុស្សប្រមាណ ៣០ ម៉ឺននាក់ ដែលជាអ្នកធ្វើការដោយប្រយោលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ក៏មានការរងផលប៉ះពាល់ផងដែរ។

## ១.២. វិធានការអន្តរាគមន៍ និងនិន្នាការនៃសេដ្ឋកិច្ចសកល

### ក. វិធានការអន្តរាគមន៍

បណ្តារដ្ឋាភិបាលជាច្រើននៅក្នុងសកលលោក បានដាក់ចេញវិធានការគោលនយោបាយចម្រុះ ក្នុងទំហំ និងទ្រង់ទ្រាយមិនធ្លាប់មានពីមុន ដើម្បីកាត់បន្ថយផលប៉ះពាល់ និងគាំទ្រសកម្មភាពសង្គម-សេដ្ឋកិច្ច សំដៅគាំពារជីវិតសង្គម និងរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន និងធុរកិច្ច ជាពិសេស ការរក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តាមការប៉ាន់ស្មាន, កញ្ចប់វិធានការអន្តរាគមន៍ ដែលបណ្តារដ្ឋាភិបាលលើសកលលោកបានដាក់ចេញ មានទំហំប្រមាណ ជាង ១០ ទ្រីលានដុល្លារអាមេរិក។

ក្នុងស្មារតីបុរេសកម្ម, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តនូវកញ្ចប់វិធានការអន្តរាគមន៍ចំនួន ១០ ជុំជាបន្តបន្ទាប់ ក្នុងគោលបំណងទ្រទ្រង់ និងស្តារសកម្មភាពអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ និងជួយទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកាប្រមាណ ៨២៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០ សម្រាប់អន្តរាគមន៍ទាំងផ្នែកសុខាភិបាល, សង្គម និងសេដ្ឋកិច្ច ហើយទំហំថវិកានេះបានកើនឡើងរហូតដល់ទៅ ១ ៤៥៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១។

ជាលទ្ធផល, កម្ពុជារក្សាបានលំនឹងជីវភាពប្រជាជន, ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា ព្រមទាំងស្ថិរភាពអត្រាប្តូរប្រាក់ និងបន្តជំរុញការ-អនុវត្តការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ក្នុងលក្ខណៈបន្ទាន់ នៅតាមការដ្ឋានចាំបាច់នានា។ ជាក់ស្តែង សម្រាប់ឆ្នាំ ២០២១, តាមការវាយតម្លៃពាក់កណ្តាលឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទោះបីជាមាន **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ"**, សេដ្ឋកិច្ចកម្ពុជាអាចនឹងសម្រេចបានអត្រាកំណើន ២,៤% ដែលគាំទ្រដោយការងើបឡើងវិញនូវសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ច ដោយឆ្លុះបញ្ចាំងតាមរយៈ៖ (១). ការរក្សាកំណើនល្អនៃការនាំចេញផលិតផលមិនមែនកាត់ដេរ ជាពិសេស អង្ករ និងផលិតផលកសិកម្មផ្សេងទៀត, កង់, គ្រឿងបង្គុំអេឡិចត្រូនិក ជាដើម, (២). ការបន្តសកម្មភាពទិញ-លក់បុរី និងផ្ទះល្វែងថ្លៃទាប និងមធ្យម ទ្រទ្រង់ដោយវិនិយោគក្នុងស្រុក និង (៣). ការបន្តកើនឡើងនូវឥណទានសម្រាប់វិស័យសំណង់ និងអចលនទ្រព្យ បើទោះបីជាមានការថមថយយ៉ាងណាក្តី។

### ខ. និន្នាការសេដ្ឋកិច្ចសកល

នៅក្នុងនិម្មាបនកម្មសេដ្ឋកិច្ចសកល, និន្នាការសំខាន់ៗមួយចំនួនដែលបាននិងកំពុងលេចឡើង មានជាអាទិ៍៖ (១). ការបន្តដាក់ចេញនូវគោលនយោបាយវិត្តារកម្ម និងកិច្ចអន្តរាគមន៍គាំទ្រផ្សេងៗ ជាពិសេស ពីសំណាក់ប្រទេសមានសេដ្ឋកិច្ចធំៗ បានកំពុងអូសទាញកំណើនសេដ្ឋកិច្ចសកល, (២). ការលេចឡើងកាន់តែច្បាស់នូវប្រព័ន្ធពហុប៉ូល និងភាពតានតឹងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច, (៣). ការជំរុញផលិតកម្មក្នុងស្រុកដើម្បីជំរុញភាពរឹងមាំនៃសេដ្ឋកិច្ចជាតិ និងកាត់បន្ថយ

ការពឹងផ្អែកលើការនាំចូល ជាពិសេសទំនិញយុទ្ធសាស្ត្រ, (៤). ការពង្រឹងតួនាទីរបស់រដ្ឋាភិបាល ដែលមានភាពចាំបាច់មិនអាចខ្វះបាននៅក្នុងការស្តារ និងជំរុញសេដ្ឋកិច្ចឱ្យងើបឡើងវិញ និង (៥). ចរន្តកាន់តែខ្លាំង និងលឿននៃការផ្លាស់ទីរោងចក្រផលិតកម្ម បង្កឡើងដោយសារឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា និងតម្រូវការក្នុងការកែប្រែរចនាសម្ព័ន្ធនៃខ្សែច្រវាក់តម្លៃ និងផ្គត់ផ្គង់សកល។

ពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ, យោងតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ, សេដ្ឋកិច្ចសកលត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ៥,៩% សម្រាប់ឆ្នាំ ២០២១ និង ៤,៩% សម្រាប់ឆ្នាំ ២០២២ ដែលអូសទាញដោយប្រទេសអភិវឌ្ឍន៍ ខណៈសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍប្រឈមនឹងការងើបឡើងវិញយឺត។ ទោះជាយ៉ាងនេះក្តី, ភាពមិនច្បាស់លាស់ដោយសារភាពយឺតយ៉ាវនៃការចាក់វ៉ាក់សាំង និងការអូសបន្លាយនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅបន្តបន្ទចំបង្អាក់ខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល។ ជាមួយគ្នានេះ, អត្រាអតិផរណា នឹងបន្តកើនឡើង ដែលបណ្តាលមកពីការកើនឡើងថ្លៃនៃវត្ថុធាតុដើមសំខាន់ៗមួយចំនួន ដូចជាចំណីអាហារ, ប្រេងឥន្ធនៈ និងសេវាដឹកជញ្ជូន។

## ១.៣. ទស្សនទស្ស័យសម្រាប់កម្ពុជា

### ក. មេរៀន និងបទពិសោធន៍ពីវិបត្តិនៃជំងឺកូវីដ-១៩

វិបត្តិនៃជំងឺកូវីដ-១៩ បានផ្តល់នូវមេរៀន និងបទពិសោធន៍ជាច្រើនដល់កម្ពុជាក្នុងការដោះស្រាយ, រៀបចំ និងដាក់ចេញនូវវិធានការគោលនយោបាយសំខាន់ៗ សម្រាប់ការកសាងសង្គម-សេដ្ឋកិច្ចមួយប្រកបដោយភាពរឹងមាំ និងបរិយាប័ន្ន នាពេលអនាគត ដូចខាងក្រោម៖

**មេរៀនទី ១. ភាពងាយរងគ្រោះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាពីការប្រែប្រួលនៃស្ថានភាព និងតម្រូវការខាងក្រៅប្រទេស៖** កម្ពុជាត្រូវកសាងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក និងជំរុញការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចឱ្យបានលឿនបំផុត ក្នុងការពង្រឹងភាពធន់នឹងវិបត្តិ ដោយចាប់ឱ្យបាននូវឧស្សាហកម្មកម្មន្តសាល ដូចជា គ្រឿងបង្គុំអេឡិចត្រូនិក និងអគ្គិសនី ព្រមទាំងគ្រឿងបង្គុំយានយន្ត និងការដំឡើងយានយន្ត ដែលមានតម្លៃបន្ថែមខ្ពស់, ឧស្សាហកម្មមានសក្តានុពលផ្សេងៗទៀត, ព្រមទាំងឧស្សាហកម្មដែលគាំទ្រ និងបម្រើឱ្យខ្សែច្រវាក់ផលិតកម្មនៅក្នុងតំបន់។

**មេរៀនទី ២. សំណាញ់សុវត្ថិភាពសង្គមជាឧបករណ៍អន្តរាគមន៍ដ៏មានប្រសិទ្ធភាពក្នុងការ-ទ្រទ្រង់សុខុមាលភាពសង្គមក្នុងពេលមានវិបត្តិ៖** ការណ៍នេះតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើការរៀបចំ, កសាង និង ពង្រឹងសមត្ថភាព ព្រមទាំងយន្តការអនុវត្ត, តាមដាន និងវាយតម្លៃ, ការសម្របសម្រួលស្ថាប័ន ជាដើម ដើម្បីលើកកម្ពស់សំណាញ់សុវត្ថិភាពសង្គម រួមទាំងការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព។

**មេរៀនទី ៣. ភាពចាំបាច់ក្នុងការរៀបចំឱ្យមានឧបករណ៍គោលនយោបាយហិរញ្ញវត្ថុ និងហិរញ្ញ-វត្ថុសាធារណៈបន្ថែមទៀត៖** កម្ពុជានឹងពង្រឹងយន្តការសម្របសម្រួល ដើម្បីចែករំលែកព័ត៌មាន និងទិន្នន័យ ក៏ដូចជារៀបចំវិធានការឆ្លើយតប, ព្រមទាំងលើកកម្ពស់សមត្ថភាពតាមដាន, វិភាគ និងវាយតម្លៃស្ថានភាពសង្គម-សេដ្ឋកិច្ច និងសមត្ថភាពអនុវត្តវិធានការនានាប្រកបដោយប្រសិទ្ធភាព និងទាន់ពេល



Scan QR Code

ក្នុងពេលមានវិបត្តិ ព្រមទាំងត្រៀម និងបង្កើនឧបករណ៍គោលនយោបាយសម្រាប់អន្តរាគមន៍ក្នុងពេលចាំបាច់។ ទន្ទឹមនេះ, កម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ពុំបានផ្តល់លក្ខខណ្ឌអំណោយផលដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយប្រសិទ្ធភាពពេញលេញក្នុងដំណាក់កាល ដែលកម្ពុជាត្រូវការគោលនយោបាយរូបិយវត្ថុ ដើម្បីជួយកាត់បន្ថយផលប៉ះពាល់នៃវិបត្តិ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

**មេរៀនទី ៤. សកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធមានចំនួនច្រើនដែលបង្កផលវិបាកកាន់តែខ្លាំងក្នុងពេលមានវិបត្តិ៖** ដោយកម្ពុជាមានអាជីវកម្ម និងធុរកិច្ចជាច្រើន ដែលមិនបានចុះបញ្ជីជាផ្លូវការ ជាពិសេសសហគ្រាសខ្នាតមីក្រូ, តូច និងមធ្យម, រាជរដ្ឋាភិបាលមានការលំបាកក្នុងការជួយឱ្យបានទាន់ពេល និងគ្រប់ជ្រុងជ្រោយ ដោយសារកង្វះទិន្នន័យ និងសូចនាករសំខាន់ៗ ដូចជា ព័ត៌មានអាជីវកម្ម, ការចុះបញ្ជី និងការងារ ជាដើម។

**មេរៀនទី ៥. ប្រាក់សន្សំរាជរដ្ឋាភិបាល ជាប្រភពហិរញ្ញប្បទានដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានានា ក្នុងអំឡុងពេលមានវិបត្តិ៖** ប្រាក់សន្សំដែលសម្រេចបានមុនពេលមានវិបត្តិ បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវកម្មវិធីអន្តរាគមន៍សង្គម-សេដ្ឋកិច្ចសំខាន់ៗ សំដៅជួយសម្រួលបន្ទុកជីវភាពប្រជាពលរដ្ឋ និងកម្មករ-និយោជិត ព្រមទាំងរក្សាលំនឹងពាណិជ្ជកម្ម។ ការណ៍នេះទាមទារឱ្យរាជរដ្ឋាភិបាលបន្តផ្តោតការគិតគូរលើការរៀបចំនូវឧបករណ៍គោលនយោបាយ សម្រាប់កៀរគរហិរញ្ញប្បទាន ដែលមានមុខងារប្រតិបត្តិរហ័ស និងមានសក្តានុពលនៅលើទីផ្សារ ដើម្បីធានានិរន្តភាពនៃការអភិវឌ្ឍទាំងក្នុងពេលធម្មតា និងពេលមានវិបត្តិ។

**មេរៀនទី ៦. ប្រព័ន្ធពន្ធត្រូវតែបន្តអភិវឌ្ឍឱ្យមានលក្ខណៈទំនើប, រឹងមាំ និងឆ្លើយតបខ្ពស់ទៅនឹងស្ថានភាពសង្គម-សេដ្ឋកិច្ច ដែលជារួមអាចចូលរួមជួយសម្រាលផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ការជឿទុកចិត្ត៖** ក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ-១៩, យន្តការពន្ធ ត្រូវបានអនុវត្ត និងមានដំណើរការល្អ ប៉ុន្តែមិនមានការដាក់សម្ពាធពន្ធដល់ប្រជាជន និងធុរជន សំដៅចូលរួមជួយសម្រួលបញ្ហាវិបូរសាច់ប្រាក់ និងដំណើរការអាជីវកម្ម ក៏ដូចជាជំរុញសកម្មភាពសេដ្ឋកិច្ច ។

## ខ. ភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា

ក្នុងបរិការណ៍នៃការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ, កម្ពុជាមានឧត្តមភាពដែលជាភាពខ្លាំងមួយចំនួន ដូចខាងក្រោម៖

**ទី១.** កម្ពុជាអាចកសាងសមត្ថភាពក្នុងវិស័យសុខាភិបាលបាន ដោយឆ្លើយតបបានរហ័សទៅនឹងស្ថានភាពនៃវិបត្តិនេះ ព្រមទាំងសម្រេចបានអត្រានៃការចាក់វ៉ាក់សាំងក្នុងអត្រាប្រមាណ ៨៨,៦១% នៃប្រជាជនសរុបចំនួន ១៦ លាននាក់ គិតត្រឹមថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០២១។

**ទី២.** ស្ថានភាពជញ្ជីងទូទាត់បន្តស្ថិតក្នុងស្ថានភាពល្អប្រសើរ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកម្រិតទុនបម្រុងអន្តរជាតិខ្ពស់ ដែលមានចំនួនប្រហែល ២០ ប៊ីលានដុល្លារអាមេរិក (គិតត្រឹមខែសីហា ឆ្នាំ ២០២១) ដែលអាចធានាការនាំចូលបានប្រមាណ ៨,៧ ខែ[1]។

[1] ក្នុងករណីមាសមិនត្រូវបានរាប់បញ្ចូល ទុនបម្រុងអន្តរជាតិអាចធានាការនាំចូលបានប្រមាណ ១១ ខែ។

**ទី៣.** លទ្ធផលនៃការប្រមូលចំណូលមានកម្រិតប្រសើរជាងអ្វីដែលធ្លាប់បានប៉ាន់ស្មាន ដោយការប្រមូលចំណូលក្នុងស្រុកសម្រាប់ឆ្នាំ ២០២០ សម្រេចបានក្នុងរង្វង់ ២១,៨១% នៃ ផសស ទោះជាមានការដាក់ចេញនូវគោលនយោបាយបន្ធូរបន្ថយពន្ធ ដើម្បីទ្រទ្រង់ដំណើរការអាជីវកម្មក្នុងអំឡុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ទី៤.** ស្ថានភាពបំណុលសាធារណៈមានភាពល្អប្រសើរ ខណៈដែលកម្ពុជានៅមានលំហសម្រាប់កៀរគរហិរញ្ញប្បទាន ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ព្រមទាំងហិរញ្ញប្បទានពីក្នុងស្រុក។ ជាការវាយតម្លៃលើសូចនាករសំខាន់ៗ, ស្ថានភាពបំណុលសាធារណៈកម្ពុជាបន្តមានចីរភាព និងស្ថិតក្នុងកម្រិតហានិភ័យទាប។

**ទី៥.** សម្រាប់វិស័យហិរញ្ញវត្ថុនៅកម្ពុជា ដែលមួយផ្នែកធំជាវិស័យធនាគារ មិនបានបង្ហាញនូវសញ្ញាណណាមួយនៃហានិភ័យខ្ពស់នោះឡើយ ទោះបីជាបន្តស្ថិតនៅក្នុងបរិបទនៃវិបត្តិនៃជំងឺកូវីដ-១៩ ក៏ដោយ។ ជាក់ស្តែង, សន្ទនីយភាពក្នុងធនាគារពាណិជ្ជ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ស្ថិតក្នុងកម្រិតប្រសើរ ក្រោមការទទួលបានការអនុគ្រោះ និងការលើកទឹកចិត្ត តាមរយៈវិធានការរបស់ធនាគារជាតិនៃកម្ពុជា ជាពិសេស វិធានការនៃការរៀបចំឥណទានឡើងវិញ។

**ទី៦.** វិស័យកសិកម្មនៅមានសក្តានុពលខ្ពស់ក្នុងការជួយទ្រទ្រង់សន្តិសុខស្បៀង ជាពិសេសការគាំទ្រកំណើន និងការស្រូបយកអ្នកអត់ការងារធ្វើ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគាំទ្រនានា និងការលើកទឹកចិត្តទាំងផ្នែកសារពើពន្ធ និងហិរញ្ញប្បទាន សំដៅជំរុញការវិនិយោគក្នុងវិស័យកសិកម្ម ក៏ដូចជាវិស័យកែច្នៃកសិកម្មឱ្យរីកចម្រើន។ ការណ៍នេះបានជួយឱ្យកម្ពុជាលើកកម្ពស់ផលិតផលកសិកម្មក្នុងស្រុក ដើម្បីបំពេញតម្រូវការប្រើប្រាស់ និងបង្កើនការនាំចេញផលិតផលកសិកម្មបានកាន់តែច្រើន។

**ទី៧.** កម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងទីផ្សារសកល, តំបន់ និងទ្វេភាគី ជាពិសេស ការចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP), កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង ដែលទើបបានការអនុម័តនាពេលថ្មីៗនេះ។ ជារួម, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងនេះដើរតួជាកម្លាំងចលករដ៏សំខាន់សម្រាប់ការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ និងការជំរុញកំណើន ប្រកបដោយចីរភាព សម្រាប់រយៈពេលវែង តាមរយៈការផ្តល់លទ្ធភាពកាន់តែទូលំទូលាយ សម្រាប់ការនាំចេញ និងការទាក់ទាញវិនិយោគបន្ថែមទៀតមកកម្ពុជា។

ទី៨. អត្រាចាប់យកបច្ចេកវិទ្យាឌីជីថល (Digital Adoption) ក៏មាននិន្នាការកើនឡើងយ៉ាងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេស ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ជាមួយគ្នានេះ, កម្ពុជាមានសក្តានុពលខ្ពស់ក្នុងការក្តាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី ៤ និងសេដ្ឋកិច្ចឌីជីថល ដោយសារ (ក). ភាគលាភប្រជាសាស្ត្រ ដែលក្នុងនោះមានយុវជនដ៏ច្រើនដែលងាយទទួលយកបច្ចេកវិទ្យាឌីជីថល, (ខ). និន្នាការកើនឡើងនូវការប្រើប្រាស់ឧបករណ៍ឆ្លាតវៃ, (គ). លំហូរវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យបច្ចេកវិទ្យា, និង (ឃ). ឥទ្ធិពលដ៏លឿននៃឌីជីថលូបនីយកម្មក្នុងគ្រប់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ ជាពិសេសក្នុងបរិបទជំងឺកូវីដ-១៩។



Scan QR Code

## ផ្នែកទី ២៖ ទស្សនាទានរួម

ផ្អែកលើការវិភាគនិន្នាការសេដ្ឋកិច្ចសកល, មេរៀន និងបទពិសោធន៍របស់កម្ពុជាពីវិបត្តិជំងឺកូវីដ-១៩ និងភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា, ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចនេះ ឈរលើទស្សនាទានរួម ដូចខាងក្រោម ៖

**ទី១.** ស្តារវិស័យដែលជាចន្ទល់នៃសេដ្ឋកិច្ច មុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩ និងទទួលរងនូវផលប៉ះពាល់ ដូចជា វិស័យទេសចរណ៍ និង កាត់ដេរ។ ទន្ទឹមនេះ, ជំរុញបន្ថែមនូវវិស័យដែលមានសក្តានុពល និងមិនថមថយនៅក្នុងវិបត្តិនៃជំងឺកូវីដ-១៩ ដូចជា វិស័យកសិកម្ម និងឧស្សាហកម្មមិនមែនកាត់ដេរ។

**ទី២.** ចាប់យកឱ្យបាននូវការផ្លាស់ប្តូរចរន្តផលិតកម្មពីសកល មកជាតំបន់ និងនិន្នាការផ្លាស់ទីរបស់រោងចក្រ ដែលកើតចេញពីសង្គ្រាមពាណិជ្ជកម្ម និងភាពតានតឹងរវាងប្រទេសមហាអំណាច។

**ទី៣.** កែទម្រង់លើកិច្ចការសំខាន់ៗ និងជាបញ្ហាប្រឈមជាក់ស្តែង ដែលអាចនាំមកនូវលទ្ធផលឆាប់រហ័ស ដើម្បីលើកកម្ពស់បរិយាកាសធុរកិច្ច និងវិនិយោគ, ភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច។

**ទី៤.** ជាផែនការដែលមានរយៈពេលខ្លីគឺ ឆ្នាំ ២០២១, ២០២២ និង ២០២៣ និងជាវិធានការគោលនយោបាយចំៗ និងថ្លឹងថ្លែងរវាងប្រសិទ្ធភាពសេដ្ឋកិច្ច, ចំណូល, ការកែទម្រង់ និងលទ្ធភាពអនុវត្តបានលឿន ដើម្បីបង្កើតបាននូវការផ្លាស់ប្តូរជាវិជ្ជមានភ្លាមៗ និងពន្លឿនចលនការសេដ្ឋកិច្ចឱ្យបានជាសារវន្ត។

**ទី៥.** ពង្រឹងមូលដ្ឋានគ្រឹះ ដើម្បីទ្រទ្រង់កំណើនសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាប័ន្ន និងធនភាព តាមរយៈការកែលម្អនូវចំណុចខ្វះខាតនាពេលកន្លងមក, ការអភិវឌ្ឍថ្មីៗនូវបច្ចេកវិទ្យា, ការកសាងធនធានមនុស្ស, ការកសាងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ។

**ទី៦.** ផ្តល់ភាពបត់បែនខ្ពស់សម្រាប់ការរៀបចំផែនការសកម្មភាព ដោយពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីកែតម្រូវ និងកែសម្រួលវិធានការគន្លឹះតាមផ្នែកនីមួយៗ ទៅតាមកាលៈទេសៈជាក់ស្តែងចំពោះមុខ ក្នុងបរិបទនៃភាពមិនច្បាស់លាស់ខ្ពស់នៃស្ថានភាពជំងឺកូវីដ-១៩ សំដៅធានានូវការអនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ទី៧.** បំពេញបន្ថែម និងពង្រឹងសង្គតិភាពជាមួយយុទ្ធសាស្ត្រ និងផែនការ នៅក្នុងវិស័យផ្សេងៗ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។

ជារួម, ឯកសារនេះ នឹងផ្តល់នូវក្របខណ្ឌរួមនៃទិសដៅគោលនយោបាយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ម្យ៉ាង និងម្យ៉ាងទៀត ដោះស្រាយបញ្ហាគន្លឹះៗជាក់ស្តែង ដែលអាចសម្រេចបាន ក្នុងរយៈពេលខ្លី ដើម្បីស្តារ និងជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចជាតិ។

### ២.១. ចក្ខុវិស័យ

ឈរលើទស្សនាទានរួមនេះ តាមរយៈក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១-២០២៣,

រាជរដ្ឋាភិបាលមានចក្ខុវិស័យ "**ពង្រឹងការកសាងមាគ៌ា និងជវភាព នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពរឹងមាំ និងចាប់យកកាលានុវត្តភាព ទាំងក្នុងនិងក្រៅប្រទេស ដើម្បីកែលម្អមូលដ្ឋានសេដ្ឋកិច្ចជាតិឱ្យមានភាពប្រកួតប្រជែង និងពិពិធកម្មខ្ពស់ ព្រមទាំងលើកកម្ពស់សុខុមាលភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យស្របទៅនឹងប្រក្រតីភាពថ្មីនៃការអភិវឌ្ឍ**"។

## ២.២. គោលបំណង និងគោលដៅ

ស្របតាមចក្ខុវិស័យនេះ, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះ មានគោលបំណង **ស្តារកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និងរយៈពេលមធ្យម ឱ្យត្រឡប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងរយៈពេលវែង**។

ដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ច តាមចក្ខុវិស័យ និងគោលបំណងខាងលើ, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះ មានគោលដៅ៖

- ស្តារវិស័យជាចន្ទល់នៃសេដ្ឋកិច្ច ដែលទទួលរងនូវផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ ដោយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងលុបបំបាត់កត្តារាំងស្ទះគន្លឹះៗតាមវិស័យ ឱ្យខាងតែបាន គួបផ្សំនឹងការចាប់យកវិស័យសក្តានុពលនៃកំណើនសេដ្ឋកិច្ច,
- កែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់កំណើន ពិពិធកម្ម និងភាពប្រកួតប្រជែង,
- ពង្រឹងភាពធន់ តាមរយៈការត្រៀមខ្លួន និងការឆ្លើយតប ដើម្បីធានាបាននូវចីរភាព និងបរិយាប័ន្ននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, និង
- សម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់យន្តការសារពើពន្ធ, ធានាស្ថិរភាពរូបិយវត្ថុ, ពង្រឹងសមតុល្យពាណិជ្ជកម្ម ក៏ដូចជា គិតគូរទៅលើយន្តការហិរញ្ញប្បទានជាដើម។

## ២.៣. អភិក្រមរួមសម្រាប់ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធី

បន្ទាប់ពីបានធ្វើការពិនិត្យ និងវាយតម្លៃអំពីស្ថានភាពនៃវិបត្តិ រួមទាំងមេរៀន និងបទពិសោធនៃវិបត្តិជំងឺកូវីដ-១៩, ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ទាមទារការដាក់ចេញនូវវិធានការគោលនយោបាយគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត។ ដោយឈរលើមូលដ្ឋាននេះ និងក្នុងទិសដៅជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាអាចងើបឡើងវិញបានឆាប់រហ័ស ស្របពេលដែលភាពមិនប្រាកដប្រជានៅមានកម្រិតខ្ពស់ ទាំងក្នុងកម្រិតប្រទេស, តំបន់ និងសកល, ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ឈរលើសសរស្តម្ភ ចំនួន **០៣ (ឬហៅថា 3Rs)** ដូចខាងក្រោម ៖

- **សសរស្តម្ភទី១-ការស្តារឡើងវិញ (Recovery)៖** តាមរយៈការជំរុញកំណើនវិស័យសំខាន់ៗ ដែលជាចន្ទល់សេដ្ឋកិច្ចមុនវិបត្តិនៃជំងឺកូវីដ-១៩ ឱ្យវិលទៅស្ថិតលើមាគ៌ានៃកំណើនឡើងវិញ ដោយផ្តោតលើការធានាសុវត្ថិភាព, ការគ្រប់គ្រងផលប៉ះពាល់, ការរក្សាលំនឹង និងការរស់ឡើងវិញនៃធុរកិច្ចដែលមានសក្តានុពល និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័សសំដៅជំរុញការងើបឡើងវិញនូវជីវភាពប្រជាជន ក៏ដូចជា អាជីវកម្មនិងធុរកិច្ច និងសង្គមទាំងមូល។



ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយ: | Scan QR Code

- **សសរស្តម្ភទី២-ការកែទម្រង់ (Reform)៖** តាមរយៈការបន្តដាក់ចេញវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមាន ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្ម សម្រាប់ការវិនិយោគនិងធុរកិច្ច ក៏ដូចជាទាញប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ សំដៅកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន, ពិពិធកម្ម និងភាព-ប្រកួតប្រជែង។
- **សសរស្តម្ភទី៣-ការកសាងភាពធន់ (Resilience)៖** តាមរយៈការពង្រឹងការត្រៀមខ្លួន និងការឆ្លើយតប ដើម្បីធានាបាននូវចីរភាព និងបរិយាប័ន្ននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក៏ដូចជាទប់ទល់នឹងជំងឺ ឬវិបត្តិស្រដៀងគ្នាដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្តោតលើការ-កសាងធនធានមនុស្ស និងជំរុញផលិតភាព, ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការ-ចាប់យកឱកាសនៃវិស័យឌីជីថល, ការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ, ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង, ការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម។

## ផ្នែកទី ៣៖ ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាតាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣

ស្របតាមទស្សនាទានរួមខាងលើ, ក្របខណ្ឌយុទ្ធសាស្ត្រនេះ កំណត់ទិសដៅគោលនយោបាយសំខាន់ៗសម្រាប់វិស័យនីមួយៗទៅតាមអភិក្រមទាំង៣ គឺការស្តារឡើងវិញ, ការកែទម្រង់ និងការកសាងភាពធន់ សំដៅផ្តល់ជាមូលដ្ឋានសម្រាប់ការរៀបចំកម្មវិធីលម្អិត និងជាក់ស្តែង ដែលអាចនឹងសម្រេចបានក្នុងរយៈពេលខ្លី ដើម្បីស្តារនិងជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចជាតិឱ្យបានខ្លាំងក្លា ជាពិសេសសម្រេចឱ្យបាននូវមូលដ្ឋានឧស្សាហកម្មរឹងមាំ និងផ្សារភ្ជាប់កាន់តែស៊ីជម្រៅជាមួយច្រវាក់ផ្គត់ផ្គង់តំបន់និងសកល ព្រមទាំងសម្រាប់ការបន្តជំរុញកំណើន, ពិពិធកម្ម និងភាពប្រកួតប្រជែង ក្នុងរយៈពេលវែង។

### ៣.១. ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ

ជាមួយនឹងការបើកប្រទេសឡើងវិញ, រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវវិធានការអប់រំ, រដ្ឋបាល និងសុខាភិបាល, កម្មវិធីជំនួយសង្គម និងអន្តរាគមន៍ផ្សេងៗ ដែលមានស្រាប់។ ទន្ទឹមនេះ ដើម្បីជំរុញការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលនឹងផ្តោតជាចម្បងក្នុងការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ (Structural Issues) ក្នុងវិស័យដែលនៅមានសក្តានុពល និងជាចន្ទល់នៃកំណើនសេដ្ឋកិច្ចដែលអាចបង្កើតនូវតម្លៃបន្ថែម ក្នុងរយៈពេលខ្លី (២០២១-២០២៣) និងជំរុញការស្ទុះងើបឡើងវិញសកម្មភាពសង្គម-សេដ្ឋកិច្ចជាតិ ទៅរកប្រក្រតីភាពថ្មីឱ្យបានឆាប់រហ័ស ជាពិសេស ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងស្ថិរភាពការងារជូនកម្មករ-និយោជិតផងដែរ។ ក្នុងន័យនេះ, ក្របខណ្ឌយុទ្ធសាស្ត្រនេះនឹងផ្តោតទៅលើការស្តារ និងជំរុញកំណើនលើវិស័យ ចំនួន ៤ រួមមាន វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, វិស័យទេសចរណ៍, វិស័យកាត់ដេរ និងវិស័យកម្មន្តសាលមិនមែនកាត់ដេរ។

## ៣.១.១. វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

នៅក្នុងពេលមានវិបត្តិនៃជំងឺកូវីដ-១៩, វិស័យកសិកម្ម និងកសិ-ឧស្សាហកម្មត្រូវបានចាត់ទុកថាជាវិស័យដែលមានសក្តានុពលខ្ពស់ក្នុងការរក្សាស្ថិរភាពសេដ្ឋកិច្ចជាតិ និងធានាបាននូវសន្តិសុខស្បៀងស្របពេលដែលវិស័យសំខាន់ៗមួយចំនួនដូចជា ទេសចរណ៍ និងសេវាកម្មគាំទ្រ ត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំង។ វិស័យនេះមិនបានទទួលរងផលប៉ះពាល់ ប៉ុន្តែជាវិស័យជួយសម្រាលបន្ទុក និងផលប៉ះពាល់ពីវិស័យផ្សេងទៀត តាមរយៈការផ្តល់ការងារ និងប្រាក់ចំណូល។ តាមការវាយតម្លៃជារួម, វិស័យកសិកម្មនៅប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ដែលការណ៍នេះបានឆ្លុះបញ្ចាំងតាមរយៈកំណើនផលិតកម្ម និងការនាំចេញ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការ-លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ទោះបីជាមានវឌ្ឍនភាពល្អប្រសើរ, វិស័យកសិកម្មនៅមានបញ្ហាប្រឈមធំៗមួយចំនួន ដែលចាំបាច់ត្រូវមានដំណោះស្រាយ រួមមាន៖ (១). កំណើនផលិតភាពទាបដែលបណ្តាលមកពីកត្តាកង្វះខាតពូជសុទ្ធ, បច្ចេកទេស, ប្រព័ន្ធស្រោចស្រព និងបច្ចេកវិទ្យាទំនើប, (២). ការធ្វើពិពិធកម្មដំណាំនៅមានកម្រិតទាប, (៣). ការយល់ដឹង និងការផ្លាស់ប្តូរគោលគំនិតរបស់ប្រជាកសិករនៅមានកម្រិតទាប, (៤). កង្វះការវិនិយោគលើការកែច្នៃ ដែលបណ្តាលមកពីថ្លៃដើមផលិតកម្មនៅមានកម្រិតខ្ពស់, (៥). ភាពមានកម្រិតនៃការធ្វើពាណិជ្ជូបនីយកម្មកសិកម្ម ពោលគឺការនាំចេញផលិតផលកសិកម្មមានលក្ខណៈក្រៅផ្លូវការ, (៦). កង្វះខាតយន្តការគាំទ្រដល់ការអនុវត្តកសិកម្មតាមកិច្ចសន្យា, (៧). កង្វះខាតហេដ្ឋា-រចនាសម្ព័ន្ធ និងប្រព័ន្ធត្រួតពិនិត្យគុណភាពផលិតផលកសិកម្ម និងធាតុចូលកសិកម្ម ដែលមានស្តង់ដារខ្ពស់ (ISO), (៨). កង្វះលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងអត្រាការប្រាក់ទាប, (៩). កង្វះហេដ្ឋា-រចនាសម្ព័ន្ធគាំទ្រអំឡុងពេល និងក្រោយពេលប្រមូលផល និង (១០). កង្វះកិច្ចសម្របសម្រួលស្ថាប័នទាំងក្នុងដំណាក់កាល នៃការធ្វើផែនការ និងការអនុវត្ត។

ដើម្បីទាញយកផលប្រយោជន៍បន្ថែមពីវិស័យកសិកម្ម សំដៅរួមចំណែកដល់ការស្តារសេដ្ឋកិច្ចឡើងវិញ, ក្របខណ្ឌយុទ្ធសាស្ត្រនេះនឹងផ្តោតជាសំខាន់លើការជំរុញកំណើនផលិតភាពកសិកម្ម, ការ-ពង្រឹងភាពប្រកួតប្រជែង ទាំងថ្លៃដើម និងគុណភាព, ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតផលកសិកម្ម, ការជំរុញការកែច្នៃផលិតផលកសិកម្ម, ការជំរុញឧស្សាហកម្មពូជដំណាំ និងការទាញយកប្រយោជន៍ឱ្យបានជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។

## ៣.១.២. វិស័យទេសចរណ៍

វិស័យទេសចរណ៍ គឺជាវិស័យទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ-១៩។ ការធ្លាក់ចុះយ៉ាងគំហុកនៃចំនួនភ្ញៀវទេសចរអន្តរជាតិ បានធ្វើឱ្យអាជីវកម្មទេសចរណ៍ជាច្រើនបានផ្អាកដំណើរការ បណ្តាលឱ្យបុគ្គលិករាប់ម៉ឺននាក់បាត់បង់ការងារ និងអ្នកដែលពឹងផ្អែកលើវិស័យនេះក្នុងការរកទទួលទានជាច្រើនបាត់បង់ចំណូល។ ទោះជាយ៉ាងនេះក្តី ចាប់ពីត្រីមាសទី ៣ ឆ្នាំ ២០២១ នេះ, ការកើនឡើងភ្ញៀវទេសចរក្នុងស្រុក អាចប៉ះប៉ូវមួយផ្នែកដល់ការបន្តធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិបន្ទាប់ពីជំងឺកូវីដ-១៩ បានស្រាកស្រាន្ត។ បន្ថែមលើបញ្ហាដែលបណ្តាលមកពីជំងឺកូវីដ-១៩, វិស័យ



ផ្ទៀងផ្ទាត់ ឯកសារផ្លូវការ: | Scan QR Code

ទេសចរណ៍កម្ពុជាក៏បាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមជារចនាសម្ព័ន្ធមួយចំនួន រួមមាន ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការធ្វើពិពិធកម្មគោលដៅផលិតផល និងសេវាទេសចរណ៍ ព្រមទាំងការបាត់បង់តម្លៃបន្ថែមសេដ្ឋកិច្ច ដោយសារអវត្តមាននៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ។

ក្នុងគន្លងនៃប្រក្រតីភាពថ្មី, ឥរិយាបថក្នុងការធ្វើដំណើរកំសាន្តរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិនឹងមានការប្រែប្រួលមួយចំនួន ដូចជា៖ និន្នាការងាកមករកការធ្វើដំណើរកំសាន្តក្នុងប្រទេសរបស់ខ្លួន ឬប្រទេសជិតខាងក្នុងតំបន់, ការធ្វើដំណើរដោយឯករាជ្យ ឬបែបក្រុមគ្រួសារ, ការបង្វែរមករកផលិតផលទេសចរណ៍បៃតងនៅតំបន់អេកូទេសចរណ៍ជាជាងរមណីយដ្ឋានប្រវត្តិសាស្ត្រ, ការប្រុងប្រយ័ត្នក្នុងការចាយវាយ និងធ្វើផែនការច្បាស់លាស់មុនធ្វើដំណើរ, និន្នាការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការកក់ និងទូទាត់ប្រាក់ ជាពិសេសការយកចិត្តទុកដាក់លើសុខភាព និងសុវត្ថិភាព។

ឆ្លើយតបនឹងនិន្នាការដំណើរកំសាន្តតាមគន្លងថ្មីនេះ, រាជរដ្ឋាភិបាលបានអនុម័តជាផ្លូវការនូវ **"ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩"** ដើម្បីតម្រង់ទិសការដាក់ចេញយុទ្ធសាស្ត្រសមស្រប និងទាន់ពេល សម្រាប់វិស័យទេសចរណ៍។ ជាមួយគ្នានេះ បន្ថែមលើការកសាងទំនុកចិត្ត និងភាពជឿជាក់សម្រាប់ទេសចរជាតិ និងអន្តរជាតិ, រាជរដ្ឋាភិបាលនឹងបន្តធ្វើពិពិធកម្មគោលដៅទេសចរណ៍ទៅតំបន់ឆ្នេរសមុទ្រ, តំបន់ភូមិភាគឦសាន្ត និងតំបន់តាមដងទន្លេមេគង្គ, ទន្លេបាសាក់ ព្រមទាំងតំបន់បឹងទន្លេសាប សំដៅបង្កើនផលិតផលទេសចរណ៍ថ្មីៗ តាមរយៈការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់ និងចាំបាច់នានា។ រាជរដ្ឋាភិបាលក៏បានអនុម័តជាផ្លូវការនូវ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥"**, **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ ២០២១-២០៣៥"** និងកំពុងរៀបចំបញ្ចប់ **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ ២០២២-២០៣៥"** ផងដែរ។

ជាទិសដៅយុទ្ធសាស្ត្រ, រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការជំរុញទេសចរណ៍ក្នុងស្រុកដែលកំពុងមានសក្តានុពល និងមានសន្ទុះងើបឡើងវិញ តាមរយៈការដាក់ឱ្យអនុវត្តនូវ **"វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣"** ក្នុងទិសដៅសម្រេចឱ្យបានចំនួនទេសចរក្នុងស្រុក ១១ លាននាក់ នៅឆ្នាំ ២០២៣។ បន្ថែមពីនេះ, **"ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង"** ក៏ត្រូវបានដាក់ចេញផងដែរ ដើម្បីបើកទទួលទេសចរណ៍សុវត្ថិភាពជាជំហានៗប្រកបដោយស្មារតីបុរេសកម្ម និងប្រុងប្រយ័ត្នក្នុងគោលដៅទាក់ទាញទេសចរអន្តរជាតិឱ្យបាន ៧ លាននាក់ត្រឹមឆ្នាំ ២០២៥។

### ៣.១.៣. វិស័យកាត់ដេរ

វិស័យកាត់ដេរ ដែលជាទូទៅរាប់បញ្ចូលផលិតកម្មស្បែកជើង និងកាបូប បានអភិវឌ្ឍជាបន្តបន្ទាប់អស់រយៈពេលជិតបីទសវត្សរ៍កន្លងមក និងបានបន្តរួមចំណែកសម្រេចនូវ សមិទ្ធផលសង្គម-សេដ្ឋកិច្ចចម្បងៗជាច្រើន រួមមាន កំណើនសេដ្ឋកិច្ច, ការនាំចេញ, ការវិនិយោគ, ការកាត់បន្ថយអត្រាភាពក្រីក្រ

និងការបង្កើតការងារ។ ទោះជាយ៉ាងនេះក្តី, វិស័យនេះក៏បានទទួលរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ គួបផ្សំនឹងបញ្ហាជារចនាសម្ព័ន្ធ ដែលធ្វើឱ្យការរីកចម្រើននៃវិស័យនេះមានភាពយឺតយ៉ាវ។ ជារួម, វិស័យនេះ នៅតែបន្តជាមជ្ឈមណ្ឌលផលិតកម្ម ដែលមានតម្លៃបន្ថែមទាប ហើយសមាហរណកម្មនៃឧស្សាហកម្ម គាំទ្រនៅក្នុងដំណើរការផ្សេងទៀតនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃនៅមានកម្រិតទាប។ បញ្ហាប្រឈមសំខាន់ៗ រួមមាន ជាអាទិ៍៖ កង្វះពលកម្មជំនាញក្នុងស្រុក ទាំងគុណភាព និងបរិមាណ និងគន្លងអាជីពសម្រាប់កម្មករ-និយោជិត ក៏ដូចជាការជំរុញផលិតភាពរបស់កម្មករ-និយោជិត, កង្វះភាពប៉ាន់ប្រមាណបាន និងស្ថិរភាពដែលបណ្តាលមកពីបញ្ហាទំនាក់ទំនងវិជ្ជាជីវៈ, លក្ខខណ្ឌការងារ និងសុខុមាលភាពកម្មករ-និយោជិតនៅមានកម្រិត, កង្វះផលិតកម្មតម្លៃបន្ថែមខ្ពស់ និងចំនួនម្ចាស់រោងចក្រ ឬអ្នកវិនិយោគក្នុងស្រុកនៅមានកម្រិតទាប, កង្វះឧស្សាហកម្មគាំទ្រនៅក្នុងវិស័យ និងបរិយាកាសធុរកិច្ចនៅមានកម្រិត, ពិពិធកម្មទីផ្សារនៅមានកម្រិត និងការពឹងផ្អែកខ្លាំងលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកង្វះកិច្ចសម្របសម្រួលអន្តរស្ថាប័ន ក្នុងចំណោមតួអង្គពាក់ព័ន្ធសំខាន់ៗ ជាដើម។ លើសពីនេះ, ការអូសបន្លាយនៃវិបត្តិនៃជំងឺកូវីដ-១៩ រហូតមកដល់បច្ចុប្បន្ន បានបង្កភាពមិនច្បាស់លាស់នៅក្នុងវិស័យកាត់ដេរ ជាពិសេស នៅក្នុងទីផ្សារធំៗរបស់កម្ពុជា។ម្យ៉ាងវិញទៀត, ស្ថានការណ៍ដែលកម្ពុជាគ្រោងនឹងឈានទៅចាកចេញពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងពេលឆាប់ៗខាងមុខ នឹងធ្វើឱ្យកម្ពុជាអាចបាត់បង់អត្ថប្រយោជន៍ជាបណ្តើរៗ ពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ជាហេតុអាចនឹងបង្កផលប៉ះពាល់ដល់វិស័យកាត់ដេរ និងផលិតសម្លៀកបំពាក់របស់កម្ពុជាបន្ថែមទៀត ដែលធ្លាប់តែពឹងផ្អែកលើប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មសម្រាប់នាំចេញទំនិញទៅទីផ្សារអន្តរជាតិសំខាន់ៗ។ បញ្ហាប្រឈម និងហានិភ័យទាំងនេះទាមទារឱ្យកម្ពុជាត្រូវគិតគូរ និងដោះស្រាយ ហើយត្រៀមខ្លួនចាប់យកកាលានុវត្តភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យនេះឱ្យកាន់តែរឹងមាំ និងមានភាពធន់ខ្ពស់។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្ត **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២១-២០២៥"** ដែលមានចក្ខុវិស័យក្នុងការអភិវឌ្ឍវិស័យនេះ ឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថាន, មានភាពធន់, មានតម្លៃបន្ថែមខ្ពស់, ផ្តោតលើផលិតផលថ្លៃខ្ពស់ និងមានលក្ខណៈពិសេស, មានភាពប្រកួតប្រជែងខ្ពស់ និងជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋកិច្ច។

## ៣.១.៤. វិស័យកម្មន្តសាលមិនមែនកាត់ដេរ

វិស័យកម្មន្តសាលមិនមែនកាត់ដេរ បាននិងកំពុងបន្តបង្ហាញនូវសញ្ញានៃការលូតលាស់យ៉ាងលឿនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនូវអត្រាកំណើននាំចេញ និងការធ្វើពិពិធកម្មទំនិញ។ ជាក់ស្តែង នៅអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩, វិស័យកម្មន្តសាលមិនមែនកាត់ដេរ នៅអាចរក្សាបានកំណើនខ្ពស់ តាមរយៈកំណើននាំចេញនៃផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ដែលរួមមាន កង់, ក្តារបន្ទះ, គ្រឿងសង្ហារិម, បន្ទះសូឡា, គ្រឿងបង្គុំអេឡិចត្រូនិក ជាដើម។

ក្នុងបរិបទនៃការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ, វិស័យនេះមានសក្តានុពលធំធេង ដើម្បីចូលរួមរុញច្រានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយម្យ៉ាង ការរំពឹងទុកនូវការបន្តនិន្នាការនៃការផ្លាស់ប្តូរទីតាំងរោងចក្រ និងការធ្វើពិពិធកម្មប្រភពផលិតកម្ម របស់ក្រុមហ៊ុនអន្តរជាតិមួយចំនួនមកកម្ពុជា, និង



Scan QR Code

ភាពអំណោយផលនៃបរិយាកាសវិនិយោគ និងធុរកិច្ច ក៏ដូចជា កំណើននៃទីផ្សារ តាមរយៈច្បាប់ស្តីពីវិនិយោគថ្មី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ជាដើម។ ទោះជាយ៉ាងនេះក្តី, វិស័យនេះនៅតែមានការប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន ដែលត្រូវដោះស្រាយចំពោះមុខ ដើម្បីបន្តពង្រឹង និងលើកកម្ពស់សមត្ថភាព និងផលិតភាព ដូចជា កង្វះវត្ថុធាតុដើមក្នុងស្រុក, ភាពមានកម្រិត និងកង្វះកម្មករជំនាញបច្ចេកទេស, កង្វះខាតប្រភេទអាជីវកម្មធុនកណ្តាល (missing middles) និងភាពមានកម្រិតក្នុងការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងតំបន់ និងសកល ដែលកំពុងបន្តរាំងវិស័យនេះក្នុងការបង្កើនសមត្ថភាពទាញយកកាលានុវត្តភាពទាំងនេះឱ្យបានជាអតិបរមា។

លើមូលដ្ឋាននេះ ជាទិសដៅទៅមុខ, រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្ត **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ដោយផ្តោតសំខាន់លើការពង្រឹង និងការពង្រីកមូលដ្ឋានឧស្សាហកម្មកម្ពុជា ជាពិសេស ទំនិញដែលមានតម្រូវការខ្ពស់ និងតម្លៃបន្ថែមខ្ពស់ ដែលអាចបម្រើតម្រូវការក្នុងស្រុកផង និងនាំចេញផង តាមរយៈការលើកកម្ពស់ការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និងសកល។

## ៣.២. ការកែទម្រង់ ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន, ពិពិធកម្ម និងភាពប្រកួតប្រជែង

ការកែទម្រង់ គឺជាកិច្ចការចាំបាច់បំផុត ដើម្បីចាប់យកកាលានុវត្តភាពនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងទាក់ទាញបន្ថែមនូវការវិនិយោគ និងធុរកិច្ច ដែលកើតចេញពីការផ្លាស់ប្តូរខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ចូលមកកាន់កម្ពុជា សំដៅចូលរួមស្តារ និងពន្លឿនការអភិវឌ្ឍវិស័យឧស្សាហកម្ម, វិស័យកសិកម្ម, និងវិស័យសេវាកម្ម ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីកែទម្រង់សំខាន់ៗ ដើម្បីដោះស្រាយបញ្ហាក្នុងកិច្ចសម្រួលពាណិជ្ជកម្ម, ការវិនិយោគ, ការធ្វើពិពិធកម្មទីផ្សារ និងការដឹកជញ្ជូន ជាដើម ដើម្បីពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈ ក្នុងលក្ខណៈបន្ទាន់នៅតាមការដ្ឋានចាំបាច់ សំដៅស្តារសេដ្ឋកិច្ច, ពង្រឹងភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីធានាចីរភាពនៃកំណើន។

ជារួម, ការរៀបចំនូវកម្មវិធី និងវិធានការក្នុងផ្នែកនេះនឹងផ្តោតសំខាន់ លើការដោះស្រាយបញ្ហាប្រឈមជាក់លាក់ ដែលអាចសម្រេចបានក្នុងរយៈពេលខ្លី និងចង្អុលបង្ហាញនូវយុទ្ធសាស្ត្រ និងទិសដៅដោះស្រាយបញ្ហាប្រឈមរយៈពេលមធ្យម និងវែង។

### ៣.២.១. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់

ការបើកចំហទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា គឺជាកិច្ចការចាំបាច់សម្រាប់ការបង្កើនភាពប្រកួតប្រជែង និងការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅកម្ពុជា។ ក្នុងរយៈកាលប៉ុន្មានឆ្នាំកន្លងមកនេះ, ទោះបីជាកម្ពុជាកំពុងប្រឈមមុខនឹងវិបត្តិនៃជំងឺកូវីដ-១៩ ក៏ដោយ, រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងនៅក្នុងការស្វែងរក និងបើកចំហទីផ្សាររបស់ខ្លួនឱ្យកាន់តែទូលាយ ដោយការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងទ្វេភាគី និងពហុភាគីនានា ដែលមាន ជាអាទិ៍ "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី កម្ពុជា-ចិន", "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី កម្ពុជា-កូរ៉េខាងត្បូង" និង "កិច្ចព្រមព្រៀងភាពជាដៃគូ

សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)" ជាដើម។ ទោះបីជាយ៉ាងនេះក្តី, កម្ពុជាមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការចាប់យកឱកាសឱ្យអស់សក្តានុពល ពីក្របខណ្ឌសមាហរណកម្មសេដ្ឋកិច្ចទាំងនេះនៅឡើយទេ តាមរយៈការចាប់យកទីផ្សារថ្មីៗដែលនៅសេសសល់ជាច្រើនទៀត ដូចជា៖ អឺរ៉ាស៊ី, អាមេរិកឡាទីន, មជ្ឈិមបូព៌ា, អាហ្វ្រិក, និងប្លុកអឺរ៉ុបខាងកើត ដែលមានភាពអំណោយផល ទាំងផ្នែកនយោបាយការបរទេស, សេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ជារួម, កម្ពុជាត្រូវតែខិតខំប្រឹងប្រែងបន្ថែមទៀតនៅក្នុងការចាប់យកឱកាសឱ្យអស់សក្តានុពលពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងទ្វេភាគី និងពហុភាគី ដែលមានស្រាប់។ ក្នុងន័យនេះ, កម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធ ដើម្បីទទួលបានផលប្រយោជន៍ជាអតិបរមា ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងនោះរួមមាន៖ កង្វះយន្តការសម្រួលពាណិជ្ជកម្ម, ត្រួតពិនិត្យ, តាមដាន និងវាយតម្លៃ, កង្វះព័ត៌មានគ្រប់គ្រាន់អំពីទីផ្សារ, សមត្ថភាពផលិតតាមស្តង់ដារ និងតម្រូវការផ្សេងៗ ជាពិសេស លើអនាម័យ និងភូតគាមអនាម័យ, របាំងបច្ចេកទេសលើពាណិជ្ជកម្ម និងគោលនយោបាយគាំពារសម្រាប់ផលិតករក្នុងស្រុក ដើម្បីបង្កើនភាពប្រកួតប្រជែង និងឆ្លើយតបនឹងតម្រូវការលក្ខខណ្ឌក្នុងការនាំចេញ។ កម្ពុជាត្រូវប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់ព័ត៌មានទីផ្សារ និងលក្ខខណ្ឌតម្រូវពីប្រទេសនាំចូល និងត្រូវបណ្តុះបណ្តាលសមត្ថភាពវិស័យឯកជន ឱ្យពួកគេអាចប្រកួតប្រជែងជាមួយទំនិញនាំចូល ក៏ដូចជាប្រកួតប្រជែងចូលទៅទីផ្សារដែលកម្ពុជា និងប្រទេសសមាជិកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដទៃទៀតទទួលបានផងដែរ។

### ៣.២.២. ការជំរុញការអនុវត្តច្បាប់វិនិយោគ

ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានបន្ទច់បង្អាក់ខ្សែច្រវាក់ផលិតកម្ម, សកម្មភាពពាណិជ្ជកម្ម, លំហូរវិនិយោគ និងការវិវត្តនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្ម ទាំងក្នុងក្របខណ្ឌក្នុងប្រទេស, តំបន់ និងសកល។ ដើម្បីបន្តជំរុញ និងទាក់ទាញលំហូរមូលធន និងវិនិយោគ ជាពិសេស វិនិយោគផ្ទាល់ពីបរទេស, រាជរដ្ឋាភិបាល បាននិងកំពុងខិតខំកែទម្រង់ជាបន្តបន្ទាប់ តាមរយៈការរៀបចំ និងដាក់ចេញនូវច្បាប់ថ្មីស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់វិនិយោគថ្មីនេះ ត្រូវបានរៀបចំឡើងដោយបានកែសម្រួល និងធ្វើឱ្យប្រសើរឡើងនូវនីតិវិធីរដ្ឋបាលពាក់ព័ន្ធទៅនឹងយន្តការស្ថាប័ន និងនីតិវិធីក្នុងការវិនិយោគ ព្រមទាំងកាត់បន្ថយរយៈពេល និងចំណាយប្រតិបត្តិការ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ និងការចុះបញ្ជីគម្រោងវិនិយោគតាមថ្នាលបច្ចេកវិទ្យា។ ជាពិសេស, ច្បាប់វិនិយោគថ្មីនេះ ផ្តល់របបលើកទឹកចិត្តប្រកបដោយភាពវៃឆ្លាត ដែលបន្ថែមការលើកទឹកចិត្តច្រើនជាងមុនសម្រាប់វិនិយោគិនក្នុងស្រុក និងបរទេស ព្រមទាំងការធានា និងការពារវិនិយោគ ទៀតផង។

ការលើកទឹកចិត្តនៅក្នុងច្បាប់ថ្មីនេះ នឹងទាក់ទាញលំហូរវិនិយោគមកកាន់វិស័យ និងសកម្មភាពវិនិយោគអាទិភាពដែលកម្ពុជាត្រូវការជាចាំបាច់ ក្នុងបរិបទនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង។ ច្បាប់នេះនឹងចូលរួមចំណែកដល់៖ (១). ការបង្កើនកម្រិតប្រើប្រាស់បច្ចេកវិទ្យា និងបច្ចេកទេសខ្ពស់, (២). ការបង្កើតការងារ និងបណ្តុះបណ្តាលជំនាញ, ការជំរុញការស្រាវជ្រាវ



ផលប្រយោជន៍ដោយសម្រួលកម្មវិធីទាញយក | Scan QR Code

ការអភិវឌ្ឍ និងនវានុវត្តន៍, (៣). ការលើកស្ទួយពិពិធកម្មសហគ្រាសធុនតូច និងមធ្យម និង (៤). ការបង្កើនការតភ្ជាប់កម្ពុជាទៅកាន់ខ្សែច្រវាក់ផលិតកម្ម ក៏ដូចជាខ្សែច្រវាក់តម្លៃតំបន់ និងសកល។

សម្រាប់ទិសដៅបន្ទាប់, រាជរដ្ឋាភិបាលនឹងពន្លឿនការដាក់ចេញនូវអនុក្រឹត្យសម្រាប់ការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដែលមានការពាក់ព័ន្ធ រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដើម្បីឱ្យក្របខណ្ឌនៃការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានេះពេញលេញ និងមានប្រសិទ្ធភាព។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏មានការចាំបាច់ក្នុងការកំណត់ឱ្យបាននូវវិស័យអាទិភាពរបស់កម្ពុជា ដែលជាទិសដៅសម្រាប់ដំណើរការអភិវឌ្ឍរបស់ប្រទេស នាពេលអនាគត ដែលមានតម្លៃបន្ថែមខ្ពស់ និងមានភាពប្រទាក់ក្រឡា ជាមួយនឹងខ្សែច្រវាក់ផលិតកម្ម និងតម្លៃតំបន់ និងសកល។

### ៣.២.៣. វិស័យអគ្គិសនី

វិស័យអគ្គិសនីនៅកម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ និងបានក្លាយជាចន្ទល់ដ៏ចម្បងដែលជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក។ មុនពេលវិបត្តិនៃជំងឺកូវីដ-១៩, សន្ទុះដ៏លឿននៃកំណើនសេដ្ឋកិច្ចកម្ពុជាបានធ្វើឱ្យតម្រូវការអគ្គិសនីកើនឡើងខ្ពស់ ទាំងក្នុងការធ្វើធុរកិច្ច និងការប្រើប្រាស់របស់ប្រជាជនទូទៅ។ នៅរដូវប្រាំងឆ្នាំ ២០១៩, តម្រូវការបានកើនខ្ពស់ជាងការគ្រោងក្នុងផែនការ គួបផ្សំជាមួយនឹងភាពរាំងស្ងួតខ្លាំង បានធ្វើឱ្យប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជាមានការខ្វះខាតប្រភពអគ្គិសនីសម្រាប់ផ្គត់ផ្គង់។ ជាការឆ្លើយតប, រាជរដ្ឋាភិបាលបានរៀបចំការវិនិយោគប្រភពអគ្គិសនីបន្ថែម តាមផែនការវិនិយោគបន្ទាន់ ដើម្បីចៀសពីការខ្វះអគ្គិសនីនេះម្តងទៀត និងកំពុងរៀបចំផែនការអភិវឌ្ឍសម្រាប់រយៈពេលវែងរហូតដល់ឆ្នាំ ២០៤០ ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីឱ្យមានគ្រប់គ្រាន់ មានស្ថិរភាព និងមានថ្លៃសមរម្យ ព្រមទាំងស្របតាមនិន្នាការពិភពលោកបច្ចុប្បន្ន។ ទោះបីជាមានវឌ្ឍនភាពល្អប្រសើរនៅក្នុងការផ្គត់ផ្គង់, វិស័យឯកជនបានស្នើឱ្យមានការអនុគ្រោះបន្ថែមទៀតពាក់ព័ន្ធនឹងថ្លៃអគ្គិសនី ជាពិសេសនៅពេលយប់, ការបន្ធូរបន្ថយសម្រួលដល់ការស្នើសុំតចរន្តអគ្គិសនី និងការពង្រឹងស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី។

ទោះស្ថិតក្នុងស្ថានភាពបច្ចុប្បន្នដែលឥន្ធនៈនានាសម្រាប់ផលិតអគ្គិសនី ទាំងធ្យូងថ្ម និងប្រេង បានឡើងថ្លៃយ៉ាងគំហុកក៏ដោយ ប៉ុន្តែដើម្បីជួយដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្រោយវិបត្តិនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានសម្រេចរក្សាថ្លៃលក់អគ្គិសនីឆ្នាំ ២០២២ ឱ្យនៅដដែលដូចឆ្នាំ ២០២១ ព្រមទាំងអនុញ្ញាតឱ្យអ្នកប្រើប្រាស់អគ្គិសនីអាចជ្រើសរើសការបង់ថ្លៃអគ្គិសនី តាមជម្រើសថ្លៃមធ្យម ឬតាមជម្រើសថ្លៃពេលយប់និងពេលថ្ងៃបូកនឹងថ្លៃអានុភាព។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលកំពុងសិក្សានិងពិនិត្យស្ថានភាព ដើម្បីរកលទ្ធភាពបន្ថយថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ ២០២៣ បន្តទៀត ក្នុងនោះរាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពកែសម្រួលរចនាសម្ព័ន្ធថ្លៃពេលយប់និងពេលថ្ងៃ បូកនឹងថ្លៃអានុភាពឡើងវិញ ដើម្បីឱ្យកាន់តែមានភាពអនុគ្រោះចំពោះការប្រើប្រាស់អគ្គិសនីពេលយប់ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យមានការធ្វើផលិតកម្មពេលយប់ សំដៅកាត់បន្ថយការប្រមូលផ្តុំតម្រូវការអគ្គិសនីនៅពេលព្រឹក និងពេលថ្ងៃ។ម្យ៉ាងវិញទៀត, ការធ្វើផលិតកម្មពេលយប់ ជាមួយថ្លៃអគ្គិសនីទាប ក៏អាច

បង្កើតជាកាលានុវត្តភាពថ្មីសម្រាប់ធុរកិច្ច ក្នុងការបង្កើនផលិតភាព ដែលអាចជួយពង្រឹងភាពប្រកួត-ប្រជែងរបស់កម្ពុជា។

បន្ថែមលើនេះ ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្មរបស់ខ្លួនកាន់តែល្អប្រសើរបន្ថែមទៀត, អគ្គិសនីកម្ពុជាដែលជាស្ថាប័នផ្គត់ផ្គង់អគ្គិសនី បាននិងកំពុងសម្រួលនីតិវិធីដល់ការស្នើសុំតចរន្តអគ្គិសនី តាមរយៈការពន្លឿនការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធអនឡាញសម្រាប់ការស្នើសុំតចរន្ត និងពន្លឿនការ-តភ្ជាប់ ដោយកាត់បន្ថយពេលកំណត់អតិបរមា សម្រាប់អតិថិជនធុនតូច និងមធ្យម។ អគ្គិសនីកម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធដាក់ពាក្យបន្តចរន្តអគ្គិសនីតាមប្រព័ន្ធអនឡាញសម្រាប់អតិថិជនធុនតូច និងកំពុងទទួលបានការចូលរួមប្រើប្រាស់សេវានេះយ៉ាងច្រើនពីអតិថិជន។

ជាមួយគ្នានេះ, ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវា និងពង្រឹងការអនុវត្តឱ្យគោរពតាមពេលកំណត់ សម្រាប់ការស្នើសុំតចរន្ត តាមរយៈការរៀបចំប្រព័ន្ធតាមដានឯកសារ និងបោះពុម្ពផ្សាយជាប្រចាំនូវស្ថិតិនៃរយៈពេលមធ្យមនៃការស្នើសុំ, អគ្គិសនីកម្ពុជាបាននិងកំពុងអនុវត្តប្រព័ន្ធគ្រប់គ្រងលំហូរឯកសារបន្តចរន្តជូនអតិថិជន (Customer Care) សម្រាប់អតិថិជនធុនតូច និងកំពុងបន្តរៀបចំបន្ថែម (Customer Care) សម្រាប់ធ្វើការតាមដានឯកសារបន្តចរន្តរបស់អតិថិជនធុនមធ្យម និងធុនធំ ដែលនឹងដាក់ឱ្យដំណើរការនាដើមឆ្នាំ ២០២២ ខាងមុខ។ ក្រៅពីនេះ, អគ្គិសនីកម្ពុជាកំពុងធ្វើការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីធានាថាការសុំច្បាប់ពាក់ព័ន្ធនានាពីអាជ្ញាធរមូលដ្ឋាននឹងត្រូវបានអនុញ្ញាតដោយប្រើពេលវេលាតិចបំផុត។

### ៣.២.៤. ការកែលម្អបរិយាកាសធុរកិច្ច

#### ក. ការស្នើសុំលិខិតអនុញ្ញាតសាងសង់

ការគ្រប់គ្រងការសាងសង់ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ជំរុញឱ្យក្រុមហ៊ុនសាងសង់ឆ្លងកាត់ដំណើរការសាងសង់ស្របច្បាប់ និងបំពេញស្តង់ដារគុណភាពសំខាន់ៗ។ ការទទួលបានភាព-ស្របច្បាប់នៃការសាងសង់នៅកម្ពុជា ត្រូវប្រើពេលវេលាយូរ និងឆ្លងកាត់នីតិវិធីច្រើន និងច្រំដែល។ ក្នុងគោលបំណងទាក់ទាញការវិនិយោគលើវិស័យសំណង់, រាជរដ្ឋាភិបាលនឹងបន្តជំរុញការរៀបចំក្រប-ខណ្ឌគតិយុត្តឱ្យបានពេញលេញ ដើម្បីផ្តល់ភាពប្រាកដប្រជា និងលើកកម្ពស់ទំនុកចិត្តដល់វិនិយោគិន។ ទន្ទឹមគ្នានេះ, រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ប្រសិទ្ធភាព, គុណភាព និងតម្លាភាព និងបន្តកែសម្រួលនីតិវិធីនៃការស្នើសុំ និងផ្តល់លិខិតអនុញ្ញាតសាងសង់ ដើម្បីលើកកម្ពស់គុណភាពសំណង់ និងធានាថាការទទួលបានភាពស្របច្បាប់នៃការសាងសង់ អាចប្រព្រឹត្តទៅបានកាន់តែលឿន និងចំណាយពេលវេលា និងថវិកាតិច។

#### ខ. ការផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យ

ការផ្ទេរអចលនទ្រព្យស្របច្បាប់នៅកម្ពុជាត្រូវឆ្លងកាត់នីតិវិធីច្រើន ខណៈដែលហេដ្ឋារចនាសម្ព័ន្ធតម្លាភាពព័ត៌មាន និងភូមិសាស្ត្រគ្របដណ្តប់របស់រដ្ឋបាលដីធ្លីនៅមានកម្រិត។ ក្នុងគោលបំណងសម្រួលដល់ដំណើរការផ្ទេរអចលនទ្រព្យ ដែលឱ្យធុរជនអាចយកអចលនទ្រព្យទៅប្រើប្រាស់ដោយស្របច្បាប់បានដោយរលូន, រាជរដ្ឋាភិបាលនឹងជំរុញ និងពន្លឿនការធ្វើទំនើបកាវូបនីយកម្ម ជាពិសេស ការរៀបចំ



ផលិតផលរបស់ សារាចរណ៍ | Scan QR Code

អភិវឌ្ឍប្រព័ន្ធមូលដ្ឋានទិន្នន័យសុរិយោដីទំនើប និងធ្វើបច្ចុប្បន្នភាពទិន្នន័យឱ្យទាន់ពេល ដោយចាប់ផ្តើមពីអចលនទ្រព្យ ដែលបានចុះបញ្ជីរួចនៅតាមតំបន់ទីប្រជុំជនធំៗ ជាពិសេស រាជធានីភ្នំពេញ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលនឹងលើកកម្ពស់ប្រសិទ្ធភាព, គុណភាព និងតម្លាភាព តាមរយៈការពន្លឿនការធ្វើវិសោធនកម្មច្បាប់ភូមិបាល និងការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធផ្សេងទៀត សំដៅកែសម្រួលការផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យ។

### គ. ការលើកកម្ពស់សេវាពន្ធដារ

ក្នុងរយៈពេល ២ ឆ្នាំ កន្លងមកនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន ដើម្បីជួយសម្រាលបន្ទុកសារពើពន្ធរបស់វិស័យឯកជន ជាពិសេស វិស័យដែលរងផលប៉ះពាល់ខ្លាំងពីវិបត្តិជំងឺកូវីដ-១៩ ដើម្បីរក្សាលំនឹងអាជីវកម្ម។ ទន្ទឹមនេះ ទោះជាមានវិបត្តិនៃជំងឺកូវីដ-១៩, អគ្គនាយកដ្ឋានពន្ធដារមិនបានដកថយពីកិច្ចការងារកែទម្រង់ ដើម្បីលើកកម្ពស់អនុលោមភាព ការផ្តល់សេវាសាធារណៈ និងការប្រមូលចំណូលជារួម។ ទោះបីជាពេលនេះ ស្ថានភាពជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្តក្តី, វិស័យមួយចំនួននៅមិនទាន់អាចវិលត្រឡប់ទៅការធ្វើធុរកិច្ចជាធម្មតាវិញទេ ដែលវិស័យទាំងនេះត្រូវការការគាំទ្រមួយរយៈបន្ថែមទៀត។ ដើម្បីជួយសម្រួលដល់ការងើបឡើងវិញរបស់វិស័យខាងលើ, រាជរដ្ឋាភិបាលនឹងបន្តរៀបចំនូវវិធានការពាក់ព័ន្ធចាំបាច់នានា ក្នុងការជួយសម្រួលបន្ទុកសារពើពន្ធដល់សហគ្រាសទាំងនេះ និងបន្តលើកកម្ពស់គុណភាពនៃការផ្តល់សេវារបស់អគ្គនាយកដ្ឋានពន្ធដារបន្ថែមទៀត។

### ឃ. ការលើកកម្ពស់សេវាគយ និងរដ្ឋាករ

ដោយសារសេដ្ឋកិច្ចរបស់កម្ពុជា គឺជាសេដ្ឋកិច្ចបើកចំហ, ការស្តារ និងការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាក្នុងបរិបទនៃជំងឺកូវីដ-១៩ ត្រូវពឹងផ្អែកលើចរន្តពាណិជ្ជកម្មអន្តរជាតិ ដែលជាកម្លាំងចលករដ៏សំខាន់ នៅក្នុងការទាក់ទាញវិនិយោគ និងការបង្កើតការងារថ្មីៗ សម្រាប់កម្លាំងពលកម្មកម្ពុជា។ នៅក្នុងបរិការណ៍នេះ, ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច, កិច្ចសម្រួលពាណិជ្ជកម្ម និងការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយពន្ធគយ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាការប្រកួតប្រជែង, ភាពទុកចិត្តរបស់ធុរជន និងការស្តារ និងការជំរុញសង្គម-សេដ្ឋកិច្ចឡើងវិញ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តអនុវត្តនូវគោលនយោបាយពន្ធគយទន់ភ្លន់ សម្រាប់វិស័យអាទិភាពមួយចំនួន, កែលម្អការផ្តល់សេវា និងជំរុញការអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ។

### ង. ការជំរុញការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីក្រុមហ៊ុន, ការចេញ C/O និងកាត់តម្រឹម ការតម្រូវឯកសារដែលមិនចាំបាច់ទាក់ទងនឹងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

រាជរដ្ឋាភិបាលនឹងជំរុញឱ្យមានការទទួលស្គាល់ដោយប្រទេសនាំចូល នូវវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមទម្រង់អេឡិចត្រូនិក ដើម្បីសម្រួលដល់ការនាំចេញបានឆាប់រហ័ស។ ដើម្បីសម្រេចបាននូវគោលដៅនេះ, ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវសម្រួលនីតិវិធី និងកាត់តម្រឹមឯកសារតម្រូវឱ្យស្របតាមកិច្ចព្រមព្រៀង និងវិធានច្បាប់ស្តីពីដើមកំណើតទំនិញ និងអនុវត្តនូវសេចក្តីសម្រេចនានា

របស់រាជរដ្ឋាភិបាល ទាក់ទងនឹងកិច្ចសម្រួលពាណិជ្ជកម្មក្នុងវេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩។ ទន្ទឹមនេះ ដើម្បីសម្រួលដល់ការធ្វើធុរកិច្ច, បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបញ្ចូលការផ្តល់សេវាសាធារណៈនៅក្រោមប្រព័ន្ធ ឬថ្នាលបច្ចេកវិទ្យារួម ដូចជា ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) និងប្រព័ន្ធបញ្ជរតែមួយជាតិ ឱ្យបានកាន់តែច្រើន។

### ច. ការរៀបចំសហគមន៍អ្នកប្រមូលផលនិងនាំចេញ និងការរៀបចំឃ្លាំង, ឡសម្ងួត និងឧបករណ៍សម្លាប់សត្វចង្រៃសម្រាប់ផលិតផលនាំចេញ

ថ្វីត្បិតក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ កម្ពុជាទទួលបានការបើកច្រកទីផ្សារពីដៃគូពាណិជ្ជកម្មលើមុខទំនិញជាច្រើនតាមរយៈប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្តី ក៏ប៉ុន្តែមុខទំនិញនាំចេញដែលជាកសិផលនៅតែជួបការលំបាក ទាំងសមត្ថភាពគោរពតាមលក្ខខណ្ឌតម្រូវផ្នែកអនាម័យ និងភូតគាមអនាម័យ, បរិមាណ និងគុណភាពផ្គត់ផ្គង់ និងពុំទាន់មានយុទ្ធសាស្ត្របង្កើនភាពប្រកួតប្រជែងដល់ផលិតករក្នុងស្រុកច្បាស់លាស់នៅឡើយ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ, ក្រសួង-ស្ថាប័នជំនាញត្រូវសហការ និងជួយគាំពារដល់វិស័យឯកជន តាមរយៈការរៀបចំយុទ្ធសាស្ត្រតាមមុខទំនិញ, ប្រមូលផ្តុំផលិតករ-អ្នកប្រមូលទិញ និងអ្នកនាំចេញតាមមុខទំនិញកសិផលនីមួយៗ ដោយបង្កើតជាសហគមន៍, ជួយសិក្សាថ្លៃដើម និងដោះស្រាយបញ្ហាប្រឈមរបស់ផលិតករ។ ការរៀបចំផែនការ និងគម្រោងទាក់ទងនឹងការជំរុញការអនុវត្តគម្រោងរៀបចំឃ្លាំង, ឡសម្ងួត និងឧបករណ៍សម្លាប់សត្វចង្រៃលើផលិតផលសម្រាប់វេចខ្ចប់មុននាំចេញ ដោយសហការជាមួយវិស័យឯកជន ក្រោមក្របខណ្ឌភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាកិច្ចការចាំបាច់បំផុត និងត្រូវសិក្សាពីប្រសិទ្ធភាព និងលទ្ធផលទទួលបានពីកិច្ចសហការនេះឱ្យបានច្បាស់លាស់ជាមុន។

## ៣.២.៥. វិស័យដឹកជញ្ជូន និងឡូជីស្ទីក

វិស័យដឹកជញ្ជូន និងឡូជីស្ទីក គឺជាវិស័យអាទិភាពមួយ ដែលរាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ តាមរយៈការវិនិយោគផ្ទាល់យ៉ាងច្រើនសន្ធឹកសន្ធាប់ ក៏ដូចជាកៀរគរវិស័យឯកជនឱ្យចូលរួមក្នុងការអភិវឌ្ឍវិស័យនេះ។ ទោះបីជានៅក្នុងដំណាក់កាលនៃវិបត្តិនៃជំងឺកូវីដ-១៩, គម្រោងវិនិយោគធំៗទាំងការវិនិយោគរបស់រដ្ឋ និងវិស័យឯកជន ដូចជាការកសាងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ, ការជួសជុល និងពង្រីកផ្លូវជាតិលេខ ៥, លេខ ២ និងលេខ ៣, គម្រោងអាកាសយានដ្ឋានថ្មីនៅទីក្រុងភ្នំពេញ, គម្រោងកសាងផែទឹកជ្រៅនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ, គម្រោងមជ្ឈមណ្ឌលភស្តុភារកម្មភ្នំពេញ និងគម្រោងដទៃទៀតជាច្រើន មិនមានការថមថយទេ។ គម្រោងវិនិយោគទាំងនេះអាចចាត់ទុកថាជាការវិនិយោគដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងទ្រង់ទ្រាយធំ នៅក្នុងវិស័យដឹកជញ្ជូន និងឡូជីស្ទីក។

ទោះបីជាមានការវិនិយោគលើគម្រោងទាំងនេះ, វិស័យដឹកជញ្ជូន និងឡូជីស្ទីកនៅប្រឈមនូវបញ្ហាចម្បងមួយចំនួន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែម និងដោះស្រាយជាប្រព័ន្ធ និងជាកញ្ចប់ ព្រមទាំងមានចក្ខុវិស័យអភិវឌ្ឍវិស័យនេះឱ្យក្លាយទៅជាវិស័យសក្តានុពលមួយ ដែលនឹង



ផលិតក្រោម ឯកសារផ្លូវការ | Scan QR Code

ជួយសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព, ប្រទាក់ក្រឡាគ្នា ព្រមទាំងចំណាយពេល និងថវិកាតិច ដើម្បីទាក់ទាញការវិនិយោគក្នុងស្រុក និងផ្ទាល់ពីបរទេស ក៏ដូចជាបម្រើជាមូលដ្ឋានគាំទ្រនៃការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់វិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈបំពេញបន្ថែមឱ្យគម្រោងធំៗទាំងនោះ និងជំរុញការរៀបចំ និងអនុវត្ត "**ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងភស្តុភារកម្ម ២០២១-២០៣០**"។

## ៣.៣. ការពង្រឹងភាពធន់ ប្រកបដោយចីរភាព និងបរិយាប័ន្ន

បទពិសោធន៍នៃការប្រឈមនឹងវិបត្តិនៃជំងឺកូវីដ-១៩ នៅក្នុងរយៈពេលជិត ២ ឆ្នាំ កន្លងមកនេះ បានបង្ហាញពីភាពចាំបាច់ក្នុងការពង្រឹងភាពធន់របស់កម្ពុជាក្នុងគ្រប់ទិដ្ឋភាព ដើម្បីធានាកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។ កម្ពុជាបានប្រឈមនឹងបញ្ហា និងហានិភ័យជាច្រើន ក្នុងនោះ សមត្ថភាពឆ្លើយតបរបស់ស្ថាប័នរាជរដ្ឋាភិបាលនៅមានកម្រិត, រចនាសម្ព័ន្ធសេដ្ឋកិច្ចងាយទទួលរងផលប៉ះពាល់, ប្រព័ន្ធគាំពារសង្គមនៅមិនទាន់រឹងមាំ និងគ្រប់ជ្រុងជ្រោយទាំងវិសាលភាពនៃការគ្របដណ្តប់ និងទំហំ ព្រមទាំងប្រព័ន្ធសុខាភិបាលនៅមានកម្រិតក្នុងការឆ្លើយតបភ្លាមៗទៅនឹងវិបត្តិ ជាដើម។ ទន្ទឹមនេះ, ប្រទេសកម្ពុជា ក៏ដូចជាសកលលោក អាចនឹងប្រឈមនឹងវិបត្តិនានាកាន់តែច្រើន រួមទាំងបញ្ហាការប្រែប្រួលអាកាសធាតុ, គ្រោះធម្មជាតិកាន់តែធំ និងញឹកញាប់, ជំងឺរាតត្បាតថ្មីៗ, វិបត្តិសេដ្ឋកិច្ច ឬវិបត្តិហិរញ្ញវត្ថុ, បញ្ហាភូមិសាស្ត្រនយោបាយ ។ល។ ដែលអាចកើតឡើងដោយគ្មានការគ្រោងទុក, កាន់តែញឹកញាប់ និងកាន់តែពិបាកក្នុងការប៉ាន់ស្មាន។ ក្នុងបរិបទនៃការកើនឡើងនៃភាពមិនប្រាកដប្រជាជាសកលទាំងនេះ, រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់ លើកិច្ចការពង្រឹងភាពធន់របស់កម្ពុជា ទាំងផ្នែកស្ថាប័នសាធារណៈ, សេដ្ឋកិច្ច, សង្គម និងបរិស្ថាន ដើម្បីធានាបាននូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន។

ជារួម, ការគិតគូរក្នុងផ្នែកនេះផ្តោតសំខាន់លើការផ្តល់ទិសដៅជាយុទ្ធសាស្ត្រ សម្រាប់ដោះស្រាយបញ្ហាប្រឈមរយៈពេលមធ្យម និងវែង ជាពិសេស ក្នុង (១). ការបន្តចាប់យក និងធ្វើបរិវត្តកម្មឌីជីថលនៅក្នុងស្ថាប័ន, សេដ្ឋកិច្ច និងសង្គមកម្ពុជា, (២). ការបន្តអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម, (៣). ការអភិវឌ្ឍជំនាញ និងការអប់រំ, (៤). ការពង្រឹង និងពង្រីកប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល, (៥). ការពង្រឹងសមត្ថភាពបន្សាំ និងសម្របខ្លួនជាមួយនឹងការផ្លាស់ប្តូរអាកាសធាតុ និង (៦). ការបន្តយកចិត្តទុកដាក់លើការអភិវឌ្ឍបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាព។

### ៣.៣.១. វិស័យឌីជីថល

ក្នុងបរិការណ៍ដែលពិភពលោកកំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិនៃជំងឺកូវីដ-១៩, បច្ចេកវិទ្យាឌីជីថល ត្រូវបានមើលឃើញថាកាន់តែមានសារៈសំខាន់ ក្នុងការជួយសម្រួលដល់ដំណើរការសកម្មភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយថែមទាំងបានក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ យ៉ាងណាមិញ, ការត្រៀមខ្លួនក្នុងការចាប់យកឌីជីថល

របស់កម្ពុជា ស្ថិតនៅដំណាក់កាលដំបូងនៅឡើយ។ ជាក់ស្តែង, កម្ពុជាស្ថិតនៅក្នុងដំណាក់កាលកំពុងបង្កើនល្បឿនចាប់យកឌីជីថលក្នុងកម្រិតទាប (Low Accelerate) ដោយមានពិន្ទុ ៩,២៧ ក្នុងចំណោម ពិន្ទុសរុប ២៥ ឬឈរនៅលេខរៀងទី ១០២ ក្នុងចំណោមប្រទេស ១៤១។ លើសពីនេះ, ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដែលជាកាតាលីករដ៏សំខាន់ ក្នុងការជំរុញការចាប់យកឌីជីថលពីសំណាក់វិស័យឯកជន និងប្រជាពលរដ្ឋទូទៅ នៅមិនទាន់ភាពប្រមូលផ្តុំនៅឡើយ ហើយភាគច្រើនមានចរិតជាកិច្ចការបណ្តោះអាសន្ន ដើម្បីដោះស្រាយបញ្ហាចំពោះមុខតែប៉ុណ្ណោះ។

ក្នុងន័យនេះ ដើម្បីស្តារសេដ្ឋកិច្ចកម្ពុជា និងជំរុញកំណើនរយៈពេលវែង ប្រកបដោយភាពធន់ និងបរិយាប័ន្ន, កម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់លើការធ្វើបរិវត្តកម្មឌីជីថល តាមរយៈ៖ (១). ការជំរុញការអនុវត្តវិធានការដែលបានដាក់ចេញក្នុង ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង (២). ការអភិវឌ្ឍ និងពង្រឹងគុណភាពសេវាសាធារណៈឌីជីថល និងថ្នាលឌីជីថលគន្លឹះ សំដៅកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលមូលដ្ឋានរបស់រដ្ឋ ក៏ដូចជាផ្តល់សម្ទុះដល់ការទទួលយកឌីជីថលពីសំណាក់ធុរជន និងប្រជាពលរដ្ឋ។

### ៣.៣.២. ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម

សហគ្រាសធុនតូច និងមធ្យមត្រូវបានកំណត់ជាចន្ទល់ និងប្រភពកំណើនសេដ្ឋកិច្ចរយៈពេលវែង និងការបង្កើតការងារសមរម្យ។ សហគ្រាសធុនតូច និងមធ្យមមានប្រមាណ ៩៨% នៃធុរកិច្ចទាំងអស់ និងបានចូលរួមដល់សេដ្ឋកិច្ចប្រមាណ ៥៨% ព្រមទាំងបានផ្តល់ការងារប្រមាណ ៧៣% នៃការងារទាំងអស់។

ការរាតត្បាតនៃជំងឺកូវីដ-១៩ បានដាក់សម្ពាធបន្ថែមដល់សហគ្រាសធុនតូច និងមធ្យម ពីលើបញ្ហារចនាសម្ព័ន្ធដែលមានស្រាប់ ជាអាទិ៍ បន្ទុកអនុលោមភាព និងកង្វះកម្លាំងពលកម្មជំនាញ និងទីផ្សារ ព្រមទាំងការទទួលបានហិរញ្ញប្បទាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ ក្នុងបរិការណ៍នៃការឆ្លងរាលដាលជំងឺកូវីដ-១៩, សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យកម្មន្តសាល និងវិស័យទេសចរណ៍ត្រូវបានវាយតម្លៃថាទទួលរងផលប៉ះពាល់អវិជ្ជមានខ្លាំងជាងនៅក្នុងវិស័យលក់ដុំ-លក់រាយ និងកសិកម្ម។ សហគ្រាសធុនតូច និងមធ្យម ត្រូវបានប៉ាន់ស្មានថា មានការប្រឈមនឹងការធ្លាក់ចុះចំណូលជាមធ្យមពីការលក់ ប្រមាណ ៥០% និងប្រឈមនឹងហានិភ័យប្រតិបត្តិការ មានជាអាទិ៍ កង្វះការទទួលបានការផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ (៤៣%), លទ្ធភាពស្វែងរកធាតុចូលផលិតកម្ម (២៧%), កង្វះការផ្គត់ផ្គង់ឥណទាន និងការពន្យារពេលទូទាត់បំណុល (២២%), កង្វះខាតវំហូរសាច់ប្រាក់ (៧៧%) និងប្រឈមនឹងការធ្លាក់ក្នុងបំណុល (១៦% ទៅ ២៩%) ជាដើម។ ការថមថយសកម្មភាពរបស់សហគ្រាសធុនតូច និងមធ្យម មានបច្ច័យអវិជ្ជមានដល់ទីផ្សារកម្លាំងពលកម្ម ដោយត្រូវបានប៉ាន់ស្មានថាសហគ្រាសធុនតូច និងមធ្យមបានកាត់បន្ថយនិយោជិត ជាមធ្យមប្រមាណ ៣០% និងកាត់បន្ថយម៉ោងការងារ និងប្រាក់បៀវត្សនិយោជិតចន្លោះពី ២៥% រហូតដល់ ២៨% ។

ក្នុងគោលដៅឆ្លើយតបការប្រឈមក្នុងដំណាក់កាលរាតត្បាតនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលនឹងដាក់ចេញវិធានការគន្លឹះដែលមានទិសដៅក្នុងការធានាប្រតិបត្តិការរបស់សហគ្រាសធុនតូច និងមធ្យម



ផ្ទៀងផ្ទាត់ឯកសារផ្លូវការ: | Scan QR Code

ក្នុងវិស័យអាទិភាព ឱ្យបន្តដំណើរការ, រស់រាន និងមានភាពធន់ ព្រមទាំងបន្តធានាស្ថិរភាពទីផ្សារការងារក្នុងស្រុក តាមរយៈការផ្តល់ឥណទានគាំទ្រវិស័យឯកជន និងការផ្តល់ការគាំទ្រដល់និយោជិតក្នុងវិស័យអាទិភាព ព្រមទាំងការបន្តដាក់ចេញវិធានការអន្តរាគមន៍ប្រទាក់ក្រឡាដទៃទៀតផងដែរ។

### ៣.៣.៣. ការអភិវឌ្ឍជំនាញ

ការអភិវឌ្ឍជំនាញសម្រាប់កម្លាំងពលកម្មកម្ពុជាប្រកបដោយគុណភាព គឺជាកត្តាគន្លឹះក្នុងការឆ្លើយតបទៅនឹងតម្រូវការជំនាញក្នុងពេលបច្ចុប្បន្ន និងអនាគតរបស់សេដ្ឋកិច្ចជាតិ សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យលើកកម្ពស់ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ព្រមទាំងបង្កើនកម្លាំងពលកម្មប្រកប ដោយចំណេះដឹង, សមត្ថភាព, ជំនាញ, ឥរិយាបថការងារ, សីលធម៌វិជ្ជាជីវៈ, ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត ជាពិសេសក្នុងបរិការណ៍នៃការកសាងមូលធនមនុស្សសម្រាប់សេដ្ឋកិច្ចឌីជីថល។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជំនាញ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការបន្តជំរុញការអនុវត្តនូវ **គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥, គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ ២០១៩-២០២៣** ដោយផ្តោតជាពិសេសលើការពង្រឹងការគ្រប់គ្រង និងគាំពារដល់ពលករទេសន្តរប្រវេសន៍ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ទៅក្នុងទីផ្សារការងារ និងសង្គមវិញ និង គំនិតផ្តួចផ្តើមសំខាន់ៗមួយចំនួនទៀត រួមមានជាអាទិ៍ មូលនិធិអភិវឌ្ឍន៍ជំនាញ, គម្រោងជំនាញ ដើម្បីភាពប្រកួតប្រជែង, ក្រុមប្រឹក្សាជំនាញតាមវិស័យ ។ល។

ជាការកត់សម្គាល់, កម្លាំងពលកម្មដែលខ្វះជំនាញសមស្រប និងប្រកបដោយគុណភាព គឺជាកត្តារាំងស្ទះដ៏សំខាន់មួយក្នុងការបង្កើនភាពប្រកួតប្រជែង ក៏ដូចជាការធ្វើពិពិធកម្មសេដ្ឋកិច្ច ដែលការណ៍នេះបានបណ្តាលឱ្យមានការលើកឡើងជាញឹកញាប់ពីសំណាក់វិស័យឯកជន រីឯបុគ្គលិកដែលគ្មានជំនាញ ឬជំនាញតិចតួច ក៏ពិបាកក្នុងការស្វែងរកការងារសមស្រប និងប្រឈមនឹងហានិភ័យខ្ពស់ក្នុងពេលមានវិបត្តិ។ ជាក់ស្តែង នៅអំឡុងពេលនៃវិបត្តិនៃជំងឺកូវីដ-១៩, កម្មករ-និយោជិត ជាពិសេសកម្មករ-និយោជិតគ្មានជំនាញ រាប់ម៉ឺននាក់ បាននិងកំពុងប្រឈមនឹងការធ្លាក់ចុះ ឬបាត់បង់ប្រាក់ចំណូលដោយសារក្រុមហ៊ុន និង/ឬ រោងចក្រ បានព្យួរ ឬបិទប្រតិបត្តិការ ដោយសារការធ្លាក់ចុះ ឬលុបចោលនូវការបញ្ជាទិញ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងដោះស្រាយបញ្ហាប្រឈមខាងលើ តាមរយៈការដាក់ចេញនូវវិធានការ ដោយផ្តោតជាសំខាន់លើកិច្ចសហការភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីអភិវឌ្ឍជំនាញ ទាំងគុណភាព និងបរិមាណឱ្យឆ្លើយតបនឹងតម្រូវការទីផ្សារការងារ ដូចជាការទទួលស្គាល់ការផ្តល់ឱកាសកម្មសិក្សាទៅនឹងកាតព្វកិច្ចហិរញ្ញប្បទានជាង និងការបណ្តុះបណ្តាលជំនាញបន្ថែមសំដៅដល់ការពង្រឹងប្រសិទ្ធភាព និងបច្ចុប្បន្នភាពជំនាញដល់កម្មករ-និយោជិត នៅក្រៅម៉ោងការងារ។

## ៣.៣.៤. ការអភិវឌ្ឍវិស័យអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្ត ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ ដែលមានគោលនយោបាយចំនួន ២ គឺ៖ (១). ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌, បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា, ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា និង (២). ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់-គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ លើសពីនេះ, ក្រសួងបានដាក់ចេញ យុទ្ធសាស្ត្រកែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដោយផ្តោតលើសសរស្តម្ភទាំង ៥ គឺ៖ (១). ការអនុវត្តសកម្មភាពគោល-នយោបាយគ្រូបង្រៀន, (២). ការពិនិត្យឡើងវិញកម្មវិធីសិក្សា, សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា, (៣). ការដាក់ឱ្យអនុវត្តអធិការកិច្ច, (៤). ការពង្រឹងវង្វាយតម្លៃសិក្សាថ្នាក់ជាតិ, តំបន់ និងអន្តរជាតិ និងការប្រឡង និង (៥). ការកែទម្រង់ឧត្តមសិក្សា ដោយរាជរដ្ឋាភិបាលបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹង ជាពិសេសតាមរយៈការបង្កើនថវិកាជូនជាលំដាប់ ដោយបានវិភាជថវិកាពី ១ ៨១៤ ប៊ីលានរៀល ឬ ២,៥% នៃ ផសស នៅក្នុងឆ្នាំ ២០១៥ ដល់ ៣ ៧៣៨ ប៊ីលានរៀល ឬ ៣,៤% នៃ ផសស ក្នុងឆ្នាំ ២០២០។

ទោះជាយ៉ាងនេះក្តី, វិបត្តិនៃជំងឺកូវីដ-១៩ ជាសកល បានបន្ថែមបន្ទុកកាន់តែខ្លាំងមកលើដំណើរការ នៃកិច្ចការកែទម្រង់វិស័យអប់រំនៅកម្ពុជា។ ជាក់ស្តែង, ការបិទដំណើរការសាលារៀនទូទាំងប្រទេស ក្នុងឆ្នាំ ២០២០ បានបង្កការរាំងស្ទះដល់ការសិក្សារបស់សិស្សនៅតាមសាលារៀនចំនួន ១៣ ៤៨២ និងប៉ះពាល់សិស្សចំនួនជាង ៣ លាននាក់។ ថ្វីត្បិតតែ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូពាក់ព័ន្ធ ក្នុងការខិតខំប្រឹងប្រែងបន្តផ្តល់ការរៀន និងបង្រៀនដល់សិស្សានុសិស្សតាមមធ្យោបាយជាច្រើន រួមទាំង ការសិក្សាពីចម្ងាយ ឬការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត, ការចាក់ផ្សាយកម្មវិធីសិក្សាតាមប៉ុស្តិ៍ទូរទស្សន៍ និងការសិក្សាតាមបណ្តុំក្តី ក៏ការរៀន និងបង្រៀនមិនបានគ្របដណ្តប់ដល់សិស្សានុសិស្សទូទាំងប្រទេស និងមិនបានតាមកម្មវិធីសិក្សាឡើយ។ លទ្ធផលនេះបណ្តាលមកពីកង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រសម្រាប់ការបង្រៀនពីចម្ងាយ, គ្រូ និងសិស្សមួយចំនួនខ្វះចំណេះដឹងផ្នែកឌីជីថល, និងមិនមានសម្ភារ ឬបរិក្ខាររៀន និងបង្រៀនគ្រប់គ្រាន់ ។ល។ ជារួម, ការបិទដំណើរការសាលារៀន បានបង្កើតហានិភ័យសំខាន់ៗ ដូចជា ការបាត់បង់ការសិក្សាកាន់តែខ្ពស់, និន្នាការនៃការ-បោះបង់ការសិក្សាកើនឡើង និងគម្លាតការសិក្សារៀនសូត្ររបស់សិស្សានុសិស្សកាន់តែធំ។

ផ្អែកលើកិច្ចខិតខំរបស់រាជរដ្ឋាភិបាល, គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន បានចាប់ផ្តើមដំណើរការរបស់ខ្លួនជាបន្តបន្ទាប់ ចាប់តាំងពីដើមខែ កញ្ញា និងបានបើកដំណើរការឡើងវិញទូទាំងប្រទេសនៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០២១។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់ចេញគោលការណ៍ប្រតិបត្តិស្តង់ដារ និងសេចក្តីណែនាំជាបន្តបន្ទាប់ ក្នុងន័យធានាដំណើរការសាលារៀន ប្រកបដោយសុវត្ថិភាព រួមមាន៖ (១). គោលការណ៍ប្រតិបត្តិស្តង់ដារ សម្រាប់ដំណើរការសាលារៀនឡើងវិញក្នុងបរិបទជំងឺកូវីដ-១៩ ស្របទៅតាម "ជីវិតរស់នៅធម្មតាតាមគន្លងបែបថ្មី", (២). សេចក្តីណែនាំ ស្តីពីការបង្រៀន និងរៀនតាមបណ្តុំសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជននៅភូមិសាស្ត្រ ដែលមានហានិភ័យទាប, (៣). គោលការណ៍ប្រតិបត្តិស្តង់ដារសម្រាប់ការលើកកម្ពស់សុខភាព និងសុវត្ថិភាពសិក្សា



Scan QR Code

ក្នុងការបង្រៀន និងរៀនតាមបណ្តុំសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន និង (៤). សេចក្តីណែនាំស្តីពីការបើកដំណើរការឡើងវិញនូវគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានរៀបចំថវិកាចាំបាច់សម្រាប់ការអនុវត្តវិធានការអនាម័យនៅតាមសាលារៀន។

ដើម្បីធានាបាននូវសេវាអប់រំប្រកបដោយគុណភាព, សមធម៌ និងបរិយាប័ន្នសម្រាប់សិស្ស និងដោះស្រាយបញ្ហាប្រឈមនានាខាងលើ ក៏ដូចជាចូលរួមចំណែកក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ជាពិសេសបន្តពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ចកម្ពុជា, ក្រសួងអប់រំ យុវជន និងកីឡា ត្រូវ៖ (១). ធានាការគ្រប់គ្រងដំណើរការសាលារៀន, ការរៀន និងការបង្រៀន ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព, (២). ដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីកៀរគរសិស្សឱ្យចូលរៀនឡើងវិញ, បង្រួមគម្លាតការសិក្សារបស់សិស្ស ព្រមទាំងពង្រឹងស្មារតីសិស្សក្នុងការសិក្សា និង (៣). បន្ត និងពន្លឿនការកែទម្រង់វិស័យអប់រំឆ្លើយតបទៅនឹងប្រក្រតីភាពថ្មី និងនិន្នាការអប់រំសកល ជាពិសេសចូលរួមអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។

### ៣.៣.៥. ប្រព័ន្ធគាំពារសង្គម

វិបត្តិសង្គម-សេដ្ឋកិច្ចនេះ បានឆ្លុះបញ្ចាំងនូវភាពចាំបាច់នៃប្រព័ន្ធគាំពារសង្គម ក្នុងការចូលរួមកាត់បន្ថយនូវផលប៉ះពាល់ ព្រមទាំងធានាបាននូវលំនឹងនៃជីវភាពរបស់ប្រជាពលរដ្ឋ។ ដើម្បីគាំទ្រ និងរក្សាលំនឹងជីវភាពរបស់ប្រជាជនក្នុងការឆ្លងកាត់វិបត្តិនៃជំងឺកូវីដ-១៩ ក្នុងស្មារតី **«មិនទុកឱ្យប្រជាជនខ្មែរណាម្នាក់ស្លាប់ដោយអត់បាយ»**, រាជរដ្ឋាភិបាលបានប្រឹងប្រែងគ្រប់គ្រងលើស្ថានភាពនៃជំងឺកូវីដ-១៩ និងរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ចចំពោះមុខបានយ៉ាងល្អប្រសើរ តាមរយៈការអនុវត្តនូវកម្មវិធីគាំពារសង្គមទាំងឡាយ ដែលជាទ្រនាប់សំណាញ់សុវត្ថិភាព។ ស្របតាមការអូសបន្លាយនៃវិបត្តិនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលនឹងបន្តអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម, បន្តឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ, ពង្រឹងការទទួលបានការគាំពារសង្គម និងពង្រីកវិសាលភាពនៃការទទួលបានការគាំពារសង្គមដល់ក្រុមប្រជាជនផ្សេងទៀត ទាំងវិស័យសេដ្ឋកិច្ចក្នុង និងក្រៅប្រព័ន្ធ។ ទោះជាយ៉ាងនេះក្តី, វិសមភាព និងភាពក្រីក្រដែលកើនឡើងពីវិបត្តិនេះ តម្រូវឱ្យមានការរៀបចំនូវកម្មវិធីគាំពារសង្គមដែលកាន់តែរឹងមាំ ទាំងវិសាលភាព (Reachability) និងទាំងទំហំ (Scalability) ដែលទន្ទឹមនេះ ត្រូវដកចេញជាបណ្តើរៗនូវកម្មវិធីជំនួយសង្គមពិសេសដែលអនុវត្តក្នុងពេលមានវិបត្តិ ដោយផ្លាស់ប្តូរទៅជាកម្មវិធី ដែលមានចីរភាពសម្រាប់ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ ក្នុងកម្រិតថវិកាដែលអាចទ្រទ្រង់បាន។

ជាទិសដៅទៅមុខ, រាជរដ្ឋាភិបាលនឹងខិតខំបន្ស៊ី និងធ្វើទំនើបកម្មប្រព័ន្ធគាំពារសង្គមដោយគិតគូរពីចីរភាពធនធាន និងតម្រូវការជាក់ស្តែង, ជាពិសេស យន្តការហិរញ្ញប្បទាន, ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី, ការធ្វើឱ្យប្រសើរឡើងនូវដំណើរការកំណត់អត្តសញ្ញាណកម្មប្រជាជនក្រីក្រ និងងាយរងគ្រោះ, ការធ្វើឌីជីថលូបនីយកម្មប្រព័ន្ធផ្តល់តាវកាលិក, ព្រមទាំងការបន្ស៊ី និងធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមនានា រួមមាន៖ (១). កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ ឆ្នាំ ដែលរស់នៅក្នុងគ្រួសារក្រីក្រ និងងាយរងគ្រោះ, (២). ការពង្រីកវិសាលភាព

នៃកម្មវិធីអាហារូបករណ៍ និងកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍, (៣). ការបង្កើតវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសមស្រប សម្រាប់យុវជនមកពីគ្រួសារក្រីក្រ ដើម្បីបង្កើតលទ្ធភាពឈោងចាប់ជំនាញ និងមុខរបរ, (៤). ការរៀបចំត្រៀមអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធនសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, (៥). ការពង្រីកវិសាលភាពកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដល់ជនមានពិការភាពក្រីក្រតាមសហគមន៍ និង (៦). ការពង្រីកវិសាលភាពនៃរបបថែទាំសុខភាព ជាដើម។

### ៣.៣.៦. វិស័យសុខាភិបាល

ជំងឺកូវីដ-១៩ នៅបន្តជាបញ្ហាប្រឈមផ្នែកប្រព័ន្ធសុខាភិបាលសាធារណៈ និងសុខុមាលភាពប្រជាជន ក៏ដូចជាសកម្មភាពសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ ដើម្បីការពារអាយុជីវិតប្រជាជន និង ជំរុញដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ច, ពាណិជ្ជកម្ម និងការធ្វើដំណើរ, ការការពារកម្ពុជាឱ្យចៀសផុតពីរលកថ្មីៗ ក៏ដូចជាមេរោគបំប្លែងថ្មី ជាពិសេស ការបើកដំណើរការសង្គម-សេដ្ឋកិច្ចឡើងវិញប្រកប ដោយភាពប្រយ័ត្នប្រយែងខ្ពស់, បុរេសកម្ម និងការថ្លឹងថ្លែងច្បាស់លាស់ គឺជាគោលដៅអាទិភាពចំពោះមុខក្នុងបរិបទនៃវិបត្តិនៃជំងឺកូវីដ-១៩។ ក្នុងបរិការណ៍នេះ សម្រាប់ដំណាក់កាលចំពោះមុខ និងរយៈពេលខ្លី, រាជរដ្ឋាភិបាលនឹងបន្តពង្រឹងសមត្ថភាពប្រព័ន្ធសុខាភិបាល, សមត្ថភាពព្យាបាលចំពោះអ្នកជំងឺកូវីដ-១៩ ដែលមានសភាពធ្ងន់ធ្ងរ ក៏ដូចជាសមត្ថភាពនៃប្រព័ន្ធអង្កេត, តាមដាន, រាយការណ៍ និងឆ្លើយតប។

មេរៀន និងបទពិសោធន៍នៃការគ្រប់គ្រង, ការកាត់បន្ថយការឆ្លងរាលដាលឱ្យនៅកម្រិតអប្បបរមា និងការការពារសុវត្ថិភាពសុខភាពសាធារណៈ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការអភិវឌ្ឍប្រព័ន្ធសុខាភិបាល ដែលមានភាពធន់ខ្ពស់ និងអាចឆ្លើយតបបានយ៉ាងរហ័ស។ ដើម្បីកសាងមូលដ្ឋានសង្គម-សេដ្ឋកិច្ចមួយដែលរឹងមាំ, ជាពិសេស ការគាំពារផ្នែកហិរញ្ញវត្ថុ, ការការពារផ្នែកសុខភាព, និងការធានាការទទួលបានសេវាសុខភាព ប្រកបដោយគុណភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប, រាជរដ្ឋាភិបាលនឹងគិតគូរជាសំខាន់លើការសម្រេចបាននូវការគ្របដណ្តប់សុខភាពជាសកល (Universal Health Coverage) សំដៅធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានដោយសមធម៌ នូវសេវាសុខភាពប្រកបដោយគុណភាព ព្រមទាំងបន្តពង្រឹងលើប្រព័ន្ធសុខាភិបាល ទាំងលើគុណភាព, ហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំយន្តការត្រៀមខ្លួនឆ្លើយតបទៅនឹងហានិភ័យសុខភាពសាធារណៈ ទៅពេលអនាគត។

### ៣.៣.៧. ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ការជំរុញភាពធន់នៃកិច្ចដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានចាត់ទុកជាអាទិភាព និងរបៀបវារៈគោលនយោបាយដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**។ ដើម្បីសម្រេចនូវគោលដៅនេះ, រាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC), ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ, ដាក់ចេញនូវបទប្បញ្ញត្តិ និងផែនការយុទ្ធសាស្ត្រជាតិនានា សំដៅកាត់បន្ថយ



Scan QR Code

ផលប៉ះពាល់ និងជំរុញការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងបានអនុវត្តការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ, ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន, ការយល់ដឹង និងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹង ការប្រែប្រួលអាកាសធាតុ និងការបន្តជំរុញអភិរក្សធនធានព្រៃឈើផងដែរ។

ផ្អែកលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពចម្បងលើ៖ (១). ការកាត់បន្ថយផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ តាមរយៈការជំរុញការវិនិយោគលើថាមពលកកើតឡើងវិញ, ប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាទំនើបៗ ដើម្បីបង្កើតថាមពល សំដៅធានាសន្តិសុខ និងស្ថិរភាពថាមពល និងការជំរុញការអភិវឌ្ឍកសិកម្ម ប្រកបដោយនិរន្តរភាព ជាដើម, (២). ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងការអភិរក្ស និងការស្តារធនធានព្រៃឈើ, ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ផ្លូវថ្នល់, ប្រព័ន្ធធារាសាស្ត្រ និងសំណង់អគារសាធារណៈ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត, ការជំរុញវិស័យឯកជនធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រក្នុងសហគ្រាសរបស់ខ្លួន ដែលបន្សាំទៅនឹងគ្រោះទឹកជំនន់ និងការកើនឡើងកម្តៅ ព្រមទាំងការជំរុញការធ្វើពិពិធកម្មកសិកម្មទៅនឹងការប្រែប្រួលអាកាសធាតុ ជាដើម និង (៣). ការពង្រឹងសមត្ថភាព និងការសម្របសម្រួលស្ថាប័ន។

### ៣.៣.៨. ការអភិវឌ្ឍបៃតង

ការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ត្រូវបានចាត់ទុកជាអាទិភាពគោលនយោបាយដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីរួមចំណែកដល់ការសម្រេចគោលដៅនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីកំណើនបៃតង, ផែនការយុទ្ធសាស្ត្រជាតិស្តីពីកំណើនសេដ្ឋកិច្ចបៃតង (២០១៣-២០៣០) និងផែនទីបង្ហាញផ្លូវស្តីពីកំណើនបៃតងជាតិ ព្រមទាំងបានអនុវត្តគម្រោងនានាពាក់ព័ន្ធនឹងការអភិវឌ្ឍបៃតងក្នុងវិស័យថាមពល, កសិកម្ម និងការកែច្នៃកាកសំណល់ជាដើម តាមរយៈការសហការជាមួយដៃគូអភិវឌ្ឍន៍នានា។ ការណ៍ទាំងនេះបានផ្តល់នូវមូលដ្ឋានគិតគូរសម្រាប់ការស្តារកំណើនបៃតងក្នុងក្របខណ្ឌយុទ្ធសាស្ត្រនេះ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងផ្តោតជាសំខាន់លើ៖ (១). ការបន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ ជាពិសេស ទឹកជំនន់ និងគ្រោះរាំងស្ងួត, (២). ការជំរុញការវិនិយោគទាំងរដ្ឋនិងឯកជនលើថាមពលកកើតឡើងវិញ និង ប្រសិទ្ធភាពថាមពល តាមរយៈយន្តការលើកទឹកចិត្តសារពើពន្ធ និងមិនមែនសារពើពន្ធ, (៣). ការជំរុញពិពិធកម្មសេដ្ឋកិច្ចទៅរកវិស័យនានា ដែលមានសក្តានុពលក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដូចជា អេកូទេសចរណ៍ និងកសិកម្ម ជាដើម, (៤). ការលើកទឹកចិត្តផ្តល់ហិរញ្ញប្បទានបៃតង និង (៥). ការបន្តជំរុញផលិតកម្ម និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព។

## ផ្នែកទី ៤៖ កម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០២១-២០២៣

ស្របជាមួយនឹងគោលបំណងជារួម ព្រមទាំងទិសដៅគោលនយោបាយជាក់លាក់ ដែលបានចង្អុលបង្ហាញ វិស័យ ឬធាតុនីមួយៗតាមផ្នែកសំខាន់ៗ នៅក្នុងក្របខណ្ឌយុទ្ធសាស្រ្តខាងលើ សំដៅស្តារសេដ្ឋកិច្ចជាតិឱ្យងើបឡើងវិញ និងពង្រឹងភាពធន់, ឯកសារនេះដាក់ចេញ "**កម្មវិធីគោលនយោបាយស្តារ និងជំរុញកំណើន**" ដែលជាផែនការរយៈពេលខ្លី សម្រាប់ឆ្នាំ ២០២១ ដល់ ២០២៣។ លើមូលដ្ឋានគិតគូរខាងលើ, កម្មវិធីគោលនយោបាយស្តារ និងជំរុញកំណើននេះនឹងដាក់ចេញនូវវិធានការគោលនយោបាយលម្អិត និងមុតស្រួច សម្រាប់អនុវត្ត និងដោះស្រាយបញ្ហាជារចនាសម្ព័ន្ធគន្លឹះៗក្នុងវិស័យ ឬអនុវិស័យនីមួយៗ ដោយមានការកំណត់ក្រសួង-ស្ថាប័នទទួលខុសត្រូវ និងពេលវេលាអនុវត្ត ជាក់លាក់។

ក្នុងន័យនេះ, វិធានការគោលនយោបាយគន្លឹះ ដែលដាក់ចេញក្នុងកម្មវិធីគោលនយោបាយស្តារ និងជំរុញកំណើន ត្រូវបានបែងចែកជា ៣ ផ្នែកសំខាន់ៗ ស្របគ្នាទៅនឹងសសរស្តម្ភទាំង ៣ ដែលរួមមាន៖ (១). ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ, (២). ការកែទម្រង់ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន, ពិពិធកម្ម និងភាពប្រកួតប្រជែង និង (៣). ការពង្រឹងភាពធន់ប្រកបដោយចីរភាព និងបរិយាប័ន្ន។ វិធានការគោលនយោបាយលម្អិត ព្រមទាំងស្ថាប័នទទួលបន្ទុក និងក្របខណ្ឌពេលវេលានៃការអនុវត្ត មានចែងនៅក្នុងបរិសិដ្ឋនៃឯកសារនេះ។

## ផ្នែកទី ៥៖ មធ្យោបាយគាំទ្រការអនុវត្តក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធី

ដូចបានគូសរំលេចក្នុងអភិក្រមខាងលើ, វិធានការដែលកំណត់ក្នុងក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចនេះ មានចរិតឆ្លើយតបផ្ទាល់ទៅនឹងគោលបំណងជាក់លាក់ ដែលបានដាក់ចេញ ប៉ុន្តែភាពជោគជ័យនៃការអនុវត្តផែនការមុតស្រួចទាំងនោះ ក៏អាស្រ័យផងដែរទៅលើ៖ (១). មូលដ្ឋាននៃជម្រើសឧបករណ៍គោលនយោបាយ ដែលមានជាអាទិ៍ គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុ និង (២). យន្តការហិរញ្ញប្បទានសំខាន់ៗ ដែលរួមមានការកៀរគរធនធានរបស់រាជរដ្ឋាភិបាល, ការគាំទ្រផ្តល់ហិរញ្ញប្បទានដល់វិស័យឯកជន និងការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ឧបករណ៍គោលនយោបាយ និងយន្តការហិរញ្ញប្បទានទាំងនេះ មានសារសំខាន់ជាសារវន្ត ក្នុងការគាំទ្រដល់ការអនុវត្តវិធានការមុតស្រួចដែលបានដាក់ចេញ ព្រមទាំងជាមធ្យោបាយ ក្នុងការជួយធានាឱ្យបាននូវលំនឹងម៉ាក្រូសេដ្ឋកិច្ច, ចីរភាពហិរញ្ញវត្ថុសាធារណៈ និងសុខុមាលភាពនៃវិស័យធនាគារ និងហិរញ្ញវត្ថុ។

### ៥.១. ជម្រើសឧបករណ៍គោលនយោបាយ

#### ក. វិធានការគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន

ការដាក់ចេញនូវគោលនយោបាយរូបិយវត្ថុបំពេញបន្ថែម និងប្រកបដោយភាពឆ្លើយតបទៅនឹងការវិវត្តនៃវិបត្តិនៃជំងឺកូវីដ-១៩ គឺពិតជាមានសារៈសំខាន់ណាស់ ក្នុងការធានាឱ្យបាននូវសុខុមាលភាពនៃវិស័យហិរញ្ញវត្ថុ និងចៀសវាងនូវសម្ពាធកាន់តែធ្ងន់ធ្ងរបន្ថែមទៀត មកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច



Scan QR Code

ដែលអាចនឹងរាំងដល់ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចលើគ្រប់វិស័យ។ ផ្អែកលើទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជា, ស្ថានភាពនៃវិស័យហិរញ្ញវត្ថុបន្តមានស្ថិរភាព និងពុំមានសញ្ញាណប្រែប្រួល គួរឱ្យកត់សម្គាល់ឡើយ។ ទោះជាយ៉ាងនេះក្តី, ហានិភ័យវិបត្តិហិរញ្ញវត្ថុនៅតែបន្តមាន ដោយសារការបន្តអូសបន្លាយនៃវិបត្តិខាងលើ ដែលអាចប៉ះពាល់ដល់សមត្ថភាពសងត្រឡប់របស់អ្នកទទួលកម្ចី ដែលកត្តានេះនឹងអាចជះឥទ្ធិពលអាក្រក់ទៅលើសន្ទនីយភាពរបស់គ្រឹះស្ថានហិរញ្ញវត្ថុក្នុងរយៈពេលខ្លី និងមធ្យម។

ជាទិសដៅសម្រាប់គោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅបន្តចូលរួមដោះស្រាយផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ និងកសាងភាពធន់នៃវិស័យធនាគារ និងហិរញ្ញវត្ថុរបស់កម្ពុជា, ធនាគារជាតិនៃកម្ពុជានឹង៖ (១). បន្តធ្វើការតាមដាន និងត្រួតពិនិត្យហានិភ័យ ជាប្រចាំទាំងកម្រិតមីក្រូ និងម៉ាក្រូ, (២). បន្តដាក់ចេញនូវវិធានការសមស្រប និងទាន់ពេល ក្នុងទិសដៅបញ្ចៀស ឬកាត់បន្ថយហានិភ័យទាំងឡាយដែលអាចកើតមាន ក៏ដូចជាដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារ និងហិរញ្ញ-វត្ថុ, និង (៣). បន្តអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយជាពិសេស នៅក្នុងបរិការណ៍ដែលការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកកំពុងកើនឡើងយ៉ាងឆាប់រហ័ស។

## ខ. វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្នុងបរិបទនៃវិបត្តិនៃជំងឺកូវីដ-១៩, ការដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈមួយដ៏ត្រឹមត្រូវ និងប្រកបដោយចក្ខុវិស័យ គឺជាយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល ក្នុងការការពារអាយុជីវិតរបស់ប្រជាជន, រក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងជីវភាពរស់នៅ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។ ក្នុងន័យនេះ ដើម្បីធ្វើឱ្យកំណើនសេដ្ឋកិច្ចត្រឡប់ទៅរកមាគ៌ាកំណើន ប្រកបដោយបរិយាប័ន្ន និងភាព-ធន់, រាជរដ្ឋាភិបាលនឹងបន្តអនុវត្ត **គោលនយោបាយវិស្តារកម្ម ដោយឈរលើគោលការណ៍ប្រសិទ្ធភាពថវិកា** តាមរយៈការរៀបចំដាក់ចេញនូវកញ្ចប់ថវិកាត្រៀមបម្រុង ដើម្បីអន្តរាគមន៍ដោះស្រាយផលប៉ះពាល់នានាដែលនៅសេសសល់ពីវិបត្តិ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានប្រើប្រាស់នូវថវិកាអន្តរាគមន៍ដ៏សន្ធឹកសន្ធាប់ប្រមាណ ៨២៩ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២០ និងប្រមាណ ១ ៤៥៤ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០២១។

ជាងនេះទៅទៀត ដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព, រាជរដ្ឋាភិបាលបានត្រៀមកញ្ចប់ថវិកាសម្រាប់ចំណាយមូលធន សរុបប្រមាណ ៦ ៥៦៥ លានដុល្លារអាមេរិក ដែលសមាមាត្រនឹង ២០,៣២% នៃ ផសស ដែលចំណាយ ៣ ០៤៦ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០២២ និង ៣ ៥១៩ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០២៣។ ក្នុងនោះ, ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស បានកើនឡើងរហូតដល់ ៣ ៤៩២ លានដុល្លារអាមេរិក និងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសប្រមាណ ៣ ០៧២ លានដុល្លារអាមេរិក។

ទិសដៅសំខាន់ៗនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ រួមមាន៖ (១). ប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យអស់លទ្ធភាព ដោយបន្តធ្វើអាទិភាវូបនីយកម្មចំណាយ សំដៅគាំទ្រដល់គោលដៅនានាដែលមានអាទិភាពខ្ពស់, (២). ដាក់ឱ្យអនុវត្តក្របខណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍ

មូលបត្ររដ្ឋ ព្រមទាំងគិតគូរក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង ជារូបិយវត្ថុជាតិ (ប្រាក់រៀល) ដែលសមមូលប្រមាណជា ៣០០ លានដុល្លារអាមេរិក, (៣). បន្តដាក់ចេញកញ្ចប់ថវិកាអន្តរាគមន៍ ដោយផ្តោតលើការអន្តរាគមន៍បែបជ្រើសរើស(Selective Measures) និងរំញោចដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច (Trigger Recovery) ដែលទាក់ទាញការវិនិយោគ និងបង្កើតការងារ និង (៤). រៀបចំដាក់ចេញនូវក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានការគិតគូរជាយុទ្ធសាស្ត្រ សំដៅធានាបានស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងចីរភាពបំណុលសាធារណៈ។

### គ. យន្តការពង្រឹងកិច្ចសហការរវាងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្នុងបរិបទវិបត្តិនៃជំងឺកូវីដ-១៩, កម្ពុជាបានប្រើប្រាស់គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុ ក្នុងន័យបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីសម្រេចគោលដៅរួម គឺរក្សាលំនឹងជីវភាពរស់នៅ, ធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។ ជាក់ស្តែង, វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលកំពុងអនុវត្តដោយរាជរដ្ឋាភិបាល រួមមាន ការលើកលែង ឬអនុគ្រោះពន្ធដល់អាជីវកម្ម, ការឧបត្ថម្ភដល់ប្រជាពលរដ្ឋ និងនិយោជិតក្នុងវិស័យ ដែលរងផលប៉ះពាល់ និងការបង្កើតការងារ តាមរយៈការជំរុញវិស័យដែលមានសក្តានុពលជាដើម។ ទន្ទឹមនេះ, ធនាគារជាតិ នៃកម្ពុជាក៏បានដាក់ចេញនូវវិធានការគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ ដោយបានចាក់បញ្ចូល សន្ទនីយភាពបន្ថែមទៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីផ្តល់លទ្ធភាពដល់គ្រឹះស្ថានទាំងនេះក្នុងការបន្ធូរបន្ថយ និងផ្តល់ឥណទានបន្ថែមដល់វិស័យដែលប៉ះពាល់។

ទោះជាយ៉ាងនេះក្តី, កិច្ចសម្របសម្រួលរវាងគោលនយោបាយទាំងពីរ ត្រូវពង្រឹងឱ្យបានកាន់តែប្រសើរថែមទៀត ក្នុងគោលដៅធានាឱ្យបាននូវការរៀបចំ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

## ៥.២. យន្តការហិរញ្ញប្បទាន

### ក. ការកៀរគរធនធានរបស់រាជរដ្ឋាភិបាល

ស្របពេលដែលវិធានការជាច្រើនត្រូវបានដាក់ចេញ សំដៅជំរុញការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច, រាជរដ្ឋាភិបាលមើលឃើញអំពីការបន្តកើនឡើងនូវតម្រូវការហិរញ្ញប្បទានដ៏សន្ធឹកសន្ធាប់ ខណៈប្រាក់សន្សំរបស់រាជរដ្ឋាភិបាលបានថមថយជាលំដាប់ បន្ទាប់ពីការធ្វើអន្តរាគមន៍ក្នុងរយៈពេលជាងមួយឆ្នាំកន្លងមក។ ក្នុងទិដ្ឋភាពនេះ ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានរដ្ឋដែលមានកម្រិត និងធានាចីរភាពហិរញ្ញវត្ថុសាធារណៈ, ការគិតគូរលើយន្តការហិរញ្ញប្បទាន នឹងផ្តោតលើការប្រើប្រាស់ធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ខណៈការកៀរគររកប្រភពហិរញ្ញប្បទានថ្មីបន្ថែម ត្រូវធ្វើឡើងដោយស្របទៅតាមលំហថវិកាដែលនៅមាន និងអនុលោមទៅតាមគោលការណ៍ដែលមានចែងក្នុង **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣។**

ជាទិសដៅសម្រាប់ការពង្រឹងយន្តការកៀរគរធនធាន, រាជរដ្ឋាភិបាលនឹង៖ (១). បន្តប្រើប្រាស់ឧបករណ៍គោលនយោបាយដែលមានស្រាប់ រួមមាន ការពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងការបន្តធ្វើវិចារណកម្មចំណាយ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងថវិការដ្ឋ



គេហទំព័រ ឯកសារផ្លូវការ | Scan QR Code

និង (២). ដាក់ចេញនូវឧបករណ៍គោលនយោបាយថ្មីៗបន្ថែមទៀត សម្រាប់ការកៀរគរហិរញ្ញប្បទាន ដែលមានសក្តានុពលនៅលើទីផ្សារ សំដៅបំពេញតម្រូវការចំពោះមុខ និងឈានទៅអភិវឌ្ឍឧបករណ៍ហិរញ្ញវត្ថុ ដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងការពង្រីកផលិតភាពកសិកម្ម ជាដើម ស្របតាមរបត់ថ្មីនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់កម្ពុជា។

### ខ. យន្តការហិរញ្ញប្បទានដល់វិស័យឯកជន

នៅក្នុងបរិការណ៍នៃការស្តារសេដ្ឋកិច្ចឡើងវិញ, ដើម្បីបន្តដំណើរការអាជីវកម្ម និងដាក់ឱ្យដំណើរការផលិតកម្មឡើងវិញ ឬពង្រីកអាជីវកម្មបន្ថែម, ការផ្តល់ឥណទានបន្ថែមជូនដល់វិស័យឯកជន ដែលស្ថិតក្នុងបណ្តាវិស័យអាទិភាព គឺជាវិធានការគន្លឹះដែលនឹងជំរុញដល់ការរស់រាន, ផលិតភាព និងការធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម តាមរយៈការចាប់យកបច្ចេកវិទ្យា ជាដើម។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវយន្តការហិរញ្ញប្បទានដល់វិស័យឯកជន តាមរយៈ៖

(១). ការត្រៀមថវិកាប្រមាណ ២៥០ លានដុល្លារអាមេរិក នៅឆ្នាំ ២០២២ សម្រាប់ផ្តល់ឥណទាន ដោយត្រង់ពីធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដែលមានអត្រាការប្រាក់ទាប ក្នុងរង្វង់ ៥% ទៅ ៥,៥% សម្រាប់វិស័យសំខាន់ៗ ដូចជា ការដាំបន្លែ, ការចិញ្ចឹមសត្វ, វារីវប្បកម្ម, ការកែច្នៃផលិតផលកសិកម្ម, វិស័យអេកូទេសចរណ៍ ឬវិស័យអាទិភាពដទៃទៀត, និង

(២). ការជំរុញឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង្កើនការផ្តល់ឥណទានបន្ថែម តាមរយៈការកែសម្រួលលក្ខខណ្ឌធានាឥណទាន របស់សាជីវកម្មធានាឥណទានកម្ពុជា ដោយពង្រីកវិសាលភាពនៃការផ្តល់ការធានាភ្ជាប់ជាមួយលក្ខខណ្ឌអនុគ្រោះ សម្រាប់វិស័យអាទិភាព ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល។

### ៥.៣. យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

ការថមថយសកម្មភាពសេដ្ឋកិច្ច គួបផ្សំនឹងការដាក់ចេញគោលនយោបាយសារពើពន្ធទន់ភ្លន់ សំដៅជួយស្រោចស្រង់វិស័យឯកជន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យមានលំនឹង មិនត្រឹមតែបានធ្វើឱ្យមានភាពអាក់រអួល និងការពិបាកដល់កិច្ចប្រឹងប្រែងប្រមូលចំណូលសារពើពន្ធប៉ុណ្ណោះទេ ថែមទាំង បង្កឱ្យមានសម្ពាធចំណាយរបស់រាជរដ្ឋាភិបាល ជាពិសេស ទៅលើវិនិយោគសាធារណៈ ដើម្បីបង្កើនផលិតភាពសេដ្ឋកិច្ច។ ក្នុងន័យនេះ, យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនជាក្របខណ្ឌសំខាន់មួយ ដែលមានគោលបំណងចម្បងកៀរគរប្រភពធនធានបន្ថែម ព្រមទាំងចំណេះដឹង, ចំណេះធ្វើ និងនវានុវត្តន៍ពីវិស័យឯកជន ឱ្យចូលរួមនៅក្នុងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ក្នុងវិស័យអាទិភាពសំខាន់ៗដែលជាមូលដ្ឋានគ្រឹះក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការពង្រឹងភាពប្រកួតប្រជែងសេដ្ឋកិច្ចរបស់កម្ពុជា ក្រោមក្របខណ្ឌយុទ្ធសាស្ត្រនេះ។ រាជរដ្ឋាភិបាលនឹងជំរុញបង្កើតក្របខណ្ឌគតិយុត្តសម្រាប់គ្រប់គ្រងលើការរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

## ផ្នែកទី ៦៖ យន្តការស្ថាប័ន និងការតាមដាន និងវាយតម្លៃ

ប្រសិទ្ធភាព និងភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការរៀបចំយន្តការស្ថាប័ន និងយន្តការត្រួតពិនិត្យ និងការវាយតម្លៃច្បាស់លាស់ប្រកបដោយឆន្ទៈនយោបាយមោះមុត និងធនធានគ្រប់គ្រាន់ ដើម្បីតាមដានលទ្ធផលនៃការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះជាប្រចាំ។ រាជរដ្ឋាភិបាលនឹងប្រើប្រាស់យន្តការដែលមានស្រាប់ គឺ **គ.ស.ហ.** ដែលជាស្ថាប័នដឹកមុខ, សម្របសម្រួល និងតាមដានលើការអនុវត្តវិធានក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះ ដែលបានដាក់ចេញ ខណៈក្រសួង-ស្ថាប័នពាក់ព័ន្ធតាមដែនសមត្ថកិច្ច មានភារកិច្ចទទួលវិធានការទាំងនេះទៅរៀបចំជាផែនការសកម្មភាពសម្រាប់ អនុវត្តជាក់ស្ដែង។ របាយការណ៍វាយតម្លៃវឌ្ឍនភាពនៃការ-អនុវត្តវិធានការទាំងនេះ នឹងត្រូវដាក់ជូនកិច្ចប្រជុំ **គ.ស.ហ.** មួយឆ្នាំម្ដង។

កម្មវត្ថុនៃក្របខណ្ឌតាមដាន និងវាយតម្លៃ គឺដើម្បីជំរុញសកម្មភាពពិភាក្សាឆ្លុះរកបញ្ហាប្រឈម, ដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង និងវាយតម្លៃប្រសិទ្ធភាពនៃយន្តការអនុវត្តវិធានការគោលនយោបាយ ដែលបានដាក់ចេញ ដោយមានការកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ និងវិធានការគោលនយោបាយដែលត្រូវអនុវត្តគន្លឹះៗភ្ជាប់ដោយស្ថាប័នទទួលខុសត្រូវនាំមុខ។ ក្នុងគោលបំណងឆ្លើយតបទៅនឹងកម្មវត្ថុនេះ, ក្របខណ្ឌនេះត្រូវបានរៀបចំឡើងតាមអភិក្រមអនុវត្តការងារ ដោយការសហការស្និតរមួត និងការចូលរួមពីសំណាក់ក្រសួង-ស្ថាប័ន, ការ-រៀបចំឱ្យមានការត្រួតពិនិត្យលទ្ធផលអនុវត្តជាប្រចាំ, ការរៀបចំឱ្យមានការពិភាក្សាគ្នាដោយសកម្មដើម្បីជំរុញការងារ និងបង្កើនការយកចិត្តទុកដាក់ និងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងលទ្ធផលជាក់ស្ដែង។

## ផ្នែកទី ៧៖ សេចក្ដីសន្និដ្ឋាន

ជារួម, **ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣** ត្រូវបានគិតគូររៀបចំឡើងក្នុងបរិការណ៍ដែលការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មាននិន្នាការថមថយក្នុងកម្រិតសមស្របមួយ ដែលអាចបង្កើតលក្ខខណ្ឌអំណោយផល ដល់ការបើកដំណើរការពេញលេញឡើងវិញ និងជាបណ្ដើរៗនូវសកម្មភាពសង្គម-សេដ្ឋកិច្ចជាតិ។

តាមរយៈការដកពិសោធន៍ និងទទួលបានមេរៀនសំខាន់ៗ ពីផលប៉ះពាល់មិនធ្លាប់មាននៃជំងឺកូវីដ-១៩ អស់រយៈពេលប្រមាណ ២ ឆ្នាំ ដែលគូសរំលេចក្នុងឯកសារនេះ, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា មានគោលដៅដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងលុបបំបាត់កត្តារាំងស្ទះគន្លឹះៗឱ្យខាងតែបាន ដើម្បីលើកកម្ពស់, ជំរុញ និងពន្លឿនចលនការសង្គម-សេដ្ឋកិច្ច ដោយ អនុលោមតាមសសរស្ដម្ភទាំង ៣ គឺ ការស្ដារឡើងវិញ, ការកែទម្រង់ និងការកសាងភាពធន់ ដែលមានចរិតបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក គួបផ្សំនឹងការគិតគូរលើទិដ្ឋភាពគោលនយោបាយម៉ាក្រូ-សេដ្ឋកិច្ចសម្រាប់គាំទ្រ និងយន្តការហិរញ្ញប្បទាន ។



Scan QR Code

ឈរលើមូលដ្ឋាននេះ ជាមួយនឹងការកំណត់នូវទិសដៅគោលនយោបាយជាយុទ្ធសាស្ត្រ តាមសសរស្តម្ភទាំង ៣ គឺការស្តារឡើងវិញ, ការកែទម្រង់ និងការកសាងភាពធន់, ឯកសារនេះក៏នឹងដាក់ចេញផងដែរនូវកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដោយកំណត់នូវវិធានការមុតស្រួចចំៗ ដែលមានកាលវេលាអនុវត្តចំនួន ២ ឆ្នាំ (២០២១-២០២៣)។ កម្មវិធីនេះផ្តោតជាសំខាន់លើការស្តារកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខ និងរយៈពេលមធ្យម តាមរយៈការលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេស សម្រេចឱ្យបាននូវមូលដ្ឋានឧស្សាហកម្មរឹងមាំ និងផ្សារភ្ជាប់កាន់តែស៊ីជម្រៅជាមួយខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល។

ដោយសារភាពមិនច្បាស់លាស់នៃស្ថានភាពជំងឺកូវីដ-១៩, ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះ មានភាពទន់ភ្លន់ និងបត់បែនខ្ពស់ ដោយត្រូវបានចាត់ទុកជា **"ឯកសាររស់"** ដែលអាចនឹងកែសម្រួលបន្ថែមជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងកាលៈទេសៈចំពោះមុខជាក់ស្តែងទាំងក្នុងប្រទេស និងសកល។ ទន្ទឹមនេះ, ភាពជោគជ័យនៃការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះ នឹងផ្តល់ជាមូលដ្ឋានដ៏មានសារៈសំខាន់ សម្រាប់ការបន្តរៀបចំរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច រួមមានយុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រជាតិ និងក្របខណ្ឌគោលនយោបាយគន្លឹះជាអាទិភាពក្រោយឆ្នាំ ២០២៣ ផងដែរ។

| ផ្នែក | ទិសដៅគោលនយោបាយ | វិធានការគោលនយោបាយគន្លឹះ | ស្ថាប័នទទួលបន្ទុក | ក្របខណ្ឌពេលវេលា |
|---|---|---|---|---|
| **៣.១. ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ** | | | | |
| ៣.១.១. | វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម | ១. ផ្តល់ឥណទានក្នុងអត្រាការប្រាក់ចន្លោះពី ៥% ទៅ ៥,៥% ក្នុងមួយឆ្នាំ ទៅកសិករ, សហគមន៍កសិកម្ម និងកសិពាណិជ្ជករ ខ្នាតតូច និងមធ្យម សម្រាប់អនុវិស័យមួយចំនួន តាមការកំណត់របស់រាជរដ្ឋាភិបាល តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB), ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា (SME Bank), កម្មវិធីសហហិរញ្ញប្បទានដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុឯកជន និងការធានាឥណទាន | - ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម<br>- ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា<br>- សាជីវកម្មធានាឥណទានកម្ពុជា | ២០២១-២០២៣ |
| | | ២.រៀបចំគម្រោងសាកល្បងនៃការផ្តល់ថវិកាបំពេញបន្ថែមទុនវិនិយោគ (Grant Matching) ចំនួន ៤០% ទៅកសិករ, ក្រុមអ្នកផលិត/សហគមន៍កសិកម្ម ដែលវិនិយោគលើការសាងសង់ផ្ទះកញ្ចក់/សំណាញ់ សម្រាប់ការដាំបន្លែលើផ្ទៃដី ចាប់ពី ០,៣ ហិកតាឡើងទៅ និងកំពុង ឬគ្រោងនឹងអនុវត្តកសិកម្មតាមកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ឬផ្តល់កម្ចីក្នុងអត្រាការប្រាក់ទាប | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០២២-២០២៣ |
| | | ៣. រៀបចំយន្តការដាក់ជាបន្ទុករបស់រដ្ឋនូវ អាករលើតម្លៃបន្ថែម (VAT) និងពន្ធនាំចូល (Tariff) លើសម្ភារៈសម្រាប់សាងសង់ផ្ទះកញ្ចក់/សំណាញ់, ទុយោតំណក់ទឹក, ទុយោបាចសាច, បំពង់ទឹបជ័រ PVC ដែលបម្រើដល់ការដាំដុះបន្លែ, សម្ភារ, គ្រឿងចក្រ, គ្រឿងម៉ាស៊ីន និងឧបករណ៍បម្រើឱ្យការផលិត, ការកែច្នៃ និងការផ្គត់ផ្គង់ផលិតផលកសិកម្ម, ម៉ាស៊ីនម្វាប់ដង្កូវរុយចោះផ្លែស្វាយ និងមៀនប៉ៃលិន, ម៉ាស៊ីនសម្រាប់បំពាក់ក្នុងបន្ទប់ត្រជាក់ផ្ទុកស្វាយស្រស់ (Chiller Machine), ប្រព័ន្ធកង្ហារត្រជាក់បំពាក់រោងចិញ្ចឹមសត្វ, ប្រព័ន្ធដាក់ចំណីសត្វស្វ័យប្រវត្តិ និង | - អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>- អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២០២១-២០២៣ |



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ | Scan QR Code

| | | | | |
|---|---|---|---|---|
| | | គ្រឿងម៉ាស៊ីន និងឧបករណ៍បម្រើឱ្យការងារកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពក្នុងក្របខណ្ឌនៃវិវឌ្ឍនាការកសិអេកូឡូស៊ី និងប្រព័ន្ធសុវត្ថិភាពស្បៀង | | |
| | | ៤. ជំរុញការវិនិយោគឯកជនលើប្រព័ន្ធដឹកជញ្ជូនត្រជាក់ តាមរយៈយន្តការដាក់ជាបន្ទុករបស់រដ្ឋនូវ អាករលើតម្លៃបន្ថែម (VAT) និងពន្ធនាំចូល (Tariff) សម្រាប់ទូកុងតឺន័រត្រជាក់ ដែលប្រើប្រាស់សម្រាប់ការដឹកជញ្ជូនផលិតផលបន្លែផ្លែឈើជាពិសេស មៀន ទៅទីផ្សារបរទេស | - អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>- អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២០២១-២០២៣ |
| | | ៥. ជំរុញឧស្សាហកម្មពូជដំណាំ, ពូជដំណាំហូបផ្លែ, ពូជបន្លែផលិតកម្មគ្រាប់, ពូជគ្រឹះ (Foundation Seeds) និងគ្រាប់ពូជវិញ្ញាបនបត្រ (Certified Seeds) នៃប្រភេទស្រូវក្រអូប (ផ្ការំដួល និងសែនក្រអូប), ពូជដំណាំដំឡូងមី និងស្វាយចន្ទី ដែលមានគុណភាព និងធន់នឹងជំងឺ និងការប្រែប្រួលអាកាសធាតុ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) | - វិទ្យាស្ថានកាឌី<br>- អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០២២-២០២៣ |
| | | ៦. ពង្រឹងសមត្ថភាពក្រុមផលិត, សមាគម និងសហគមន៍កសិកម្មមៀន, ទុរេន និងចេក និងជំរុញការអនុវត្តកសិកម្មតាមកិច្ចសន្យារវាងក្រុមផលិត, សមាគម និងសហគមន៍កសិកម្ម និង ក្រុមហ៊ុនប្រមូលទិញ និងកែច្នៃផលិតផលកសិកម្ម | - នាយកដ្ឋានកសិ-ឧស្សាហកម្ម<br>- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០២១-២០២៣ |

| | | | | |
|---|---|---|---|---|
| | | ៧. ពង្រឹងការផ្សព្វផ្សាយអំពីការអនុវត្តកសិកម្មល្អនិងការបំពេញលក្ខខណ្ឌតម្រូវអនាម័យ និងភូតគាមអនាម័យ សម្រាប់ផលិតផលស្វាយ, មៀនប៉ៃលិន, ម្រេច, ទុរេន និងដូងក្រអូប ទៅដល់កសិករ, ក្រុមផលិត និងសហគមន៍កសិកម្ម | - អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០២២ |
| | | ៨. ពង្រឹងការផ្សព្វផ្សាយអំពីការអនុវត្តវារីវប្បកម្មល្អ និងការត្រួតពិនិត្យកាកសំណល់សារធាតុគីមីផ្សេងៗលើផលិតផលវារីវប្បកម្ម ជាពិសេស ត្រីប្រា ទៅដល់វារីវប្បករ ដើម្បីនាំចេញផលិតផលត្រីប្រាចិញ្ចឹម ទៅប្រទេសចិន | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០២២ |
| | | ៩. បន្តជំរុញការវិនិយោគ និងថែទាំប្រព័ន្ធស្រោចស្រពខ្នាតតូច ដែលតភ្ជាប់ពីប្រឡាយមេ និងផ្លូវលំជនបទ តាមរយៈយន្តការនៃគម្រោងសាច់ប្រាក់ពលកម្ម (Cash For Work) | - ក្រសួងធនធានទឹក និងឧតុនិយម<br>- ក្រសួងអភិវឌ្ឍន៍ជនបទ | ២០២១-២០២៣ |
